# សេចក្ដីសង្កេតសន្និដ្ឋានរួម
# របស់គណៈកម្មាធិការ នៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស្ដីពី
# ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី សម្រាប់ប្រទេសកម្ពុជា
# ២០១៩


គាំទ្រថវិកាដោយ

សំឡេង

សហភាពអឺរ៉ុប

DCA actalliance

HEINRICH BÖLL STIFTUNG

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

The Cambodian NGO Committee on CEDAW

NGO-CEDAW

# សេចក្តីផ្តើម

សេចក្តីសង្កេតសន្និដ្ឋានរួម របស់គណៈកម្មាធិការ នៃអង្គការសហប្រជាជាតិ ទទួលបន្ទុកអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (សេចក្តីសង្កេតសន្និដ្ឋានរួម) គឺជាឯកសារមួយ ដែលត្រូវបានបង្កើតឡើងក្នុងចំណោមឯកសារគោលនានា នៃវដ្តរបាយការណ៍របស់អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (អនុសញ្ញា ស៊ីដ)។ គណៈកម្មាធិការ នៃអង្គការសហប្រជាជាតិ ទទួលបន្ទុកអនុសញ្ញា ស៊ីដ (គណៈកម្មាធិការ) ជាទូទៅដាក់ចេញឯកសារនេះ បន្ទាប់ពីបានត្រួតពិនិត្យ តាមរយៈការជួបប្រជុំដោយផ្ទាល់លើរបាយការណ៍របស់រដ្ឋភាគី ដើម្បីផ្តល់នូវការណែនាំជាក់លាក់ដែលនាំអោយមានភាពប្រសើរឡើង ក្នុងការអនុវត្តអនុសញ្ញា ស៊ីដ នៅក្នុងបរិបទជាតិ។ សេចក្តីសង្កេតសន្និដ្ឋានរួម ជាឯកសារដ៏មានសារៈសំខាន់ សម្រាប់ការងារទាក់ទងទៅនឹងការលើកកម្ពស់សមភាពយេនឌ័រ។

បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា ស៊ីដ នៅក្នុងឆ្នាំ១៩៩២ មក ប្រទេសកម្ពុជាបានឆ្លងកាត់ការត្រួតពិនិត្យដោយគណៈកម្មាធិការចំនួន ៣លើក។ ការត្រួតពិនិត្យលើរបាយការណ៍ប្រទេសកម្ពុជាលើកទី១ ធ្វើឡើងបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាបានដាក់ជូនរបាយការណ៍ជាតិ គួបលើក១ ទី២ និងទី៣ ទៅ គណៈ-កម្មាធិការ នៅឆ្នាំ២០០៣។ តំណាងប្រតិភូរបស់រាជរដ្ឋាភិបាលកម្ពុជាបានជួបប្រជុំផ្ទាល់ជាមួយគណៈកម្មាធិការនៅក្នុងសម័យប្រជុំទី៣៤ នៃអនុសញ្ញា ស៊ីដ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៦ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ហើយប្រទេសកម្ពុជាទទួលបានសេចក្តីសង្កេតសន្និដ្ឋានរួមលើកទី១ (ពីមុនហៅថា ការផ្តល់មតិសន្និដ្ឋានចុងក្រោយ) ក្នុងឆ្នាំ២០០៦។

ការត្រួតពិនិត្យលើរបាយការណ៍ប្រទេសកម្ពុជាលើកទី២ ធ្វើឡើងនៅក្នុងសម័យប្រជុំទី៥៦ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដែលឆ្លើយតបទៅនឹងរបាយការណ៍ជាតិគួបលើកទី ៤ និងទី៥ ដែលដាក់ជូនទៅគណៈកម្មាធិការនៅឆ្នាំ២០១០ ហើយប្រទេសកម្ពុជាទទួលបានសេចក្តីសង្កេតសន្និដ្ឋានរួមលើកទី២ ក្នុងឆ្នាំ២០១៣។

ការត្រួតពិនិត្យលើរបាយការណ៍ប្រទេសកម្ពុជាលើកទី៣ គឺឆ្លើយតបទៅនឹងរបាយការណ៍ជាតិលើកទី៦ ដែលដាក់ជូនទៅគណៈកម្មាធិការនៅឆ្នាំ២០១៨ ហើយប្រព្រឹត្តឡើងនៅក្នុងសម័យប្រជុំទី៧៤ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩ ។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនគណៈប្រតិភូជាតំណាងចំនួន ២០រូប ដែលចាត់តាំងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ទៅចូលរួមដោយផ្ទាល់ក្នុងកិច្ចប្រជុំ ដើម្បីធ្វើការឆ្លើយតបទៅនឹងសំនួររបស់គណៈកម្មាធិការនៅក្នុងកិច្ចប្រជុំនេះ។ ក្នុងខណៈនេះដែរ ក៏មានតំណាងចំនួន ២០រូប ពីអង្គការសង្គមស៊ីវិលកម្ពុជា (តំណាង១៦រូបមកពីអង្គការចំនួន១១[១] ដែលជាអង្គការសមាជិកនិងដៃគូរបស់ NGO-CEDAW) បានធ្វើដំណើរទៅចូលរួមដែរ ដើម្បីផ្តល់បទបង្ហាញផ្ទាល់មាត់នៃសេចក្តីថ្លែងការណ៍របស់សង្គមស៊ីវិល និងឆ្លើយតបនូវសំនួរផ្សេងៗ របស់គណៈកម្មាធិការ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ គណៈកម្មាធិការបានដាក់ចេញនូវសេចក្តី-សង្កេតសន្និដ្ឋានរួមលើកទី៣ សម្រាប់ប្រទេសកម្ពុជា នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩ ។ នៅក្នុងសេចក្តីសង្កេត-សន្និដ្ឋានរួមនេះ គណៈកម្មាធិការបានធ្វើការកត់សម្គាល់ចំពោះរាជរដ្ឋាភិបាលកម្ពុជា លើដំណើរការរីកចម្រើននៃសមភាពយេនឌ័រ ហើយក៏បង្ហាញឡើងនូវការព្រួយបារម្ភចំពោះឧបសគ្គនានាដែលស្ត្រីនិងក្មេងស្ត្រីកម្ពុជា នៅតែប្រឈមនិងកំណត់នូវវិធានការបន្ទាន់និងមានប្រសិទ្ធិបំផុត ដែលត្រូវយកមកធ្វើការអនុវត្តអនុសញ្ញា ស៊ីដ នៅក្នុងរយៈពេល ៤ឆ្នាំបន្ទាប់។

[១] គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW) សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ) អង្គការក្លាហាន អង្គការបន្ទាយស្រី សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) មជ្ឈមណ្ឌលអាមេរិកកាំងសំរាប់សាមគ្គីភាពការងារអន្តរជាតិ (អេស៊ីលស៍) មូលនិធិហេនរេចបូលស្ទីហ្វទង់ (HBF) អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់) អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (ឆេក) និងអង្គការពិភពកុមារ និងអភិវឌ្ឍន៍ (PE&D)

NGO-CEDAW បានបន្ថែមបឋមកថា និងលេខទំព័រ ហើយបានកែទម្រង់នៃឯកសារដើម។ ប៉ុន្តែអត្ថបទជាភាសាអង់គ្លេស គឺដូចឯកសារដើម ដែលបោះផ្សាយក្នុងគេហទំព័រ៖ https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW/C/KHM/CO/6&Lang=En

United Nations
Convention on the Elimination of All Forms of Discrimination against Women

Distr.: General
12 November 2019

Original: English

# គណៈកម្មាធិការ នៃអនុសញ្ញាសហប្រជាជាតិទទួលបន្ទុកអនុសញ្ញា ស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី

សេចក្ដីសង្កេតសន្និដ្ឋានរួម ទៅលើរបាយការណ៍តាមកាលកំណត់លើកទី៦ សម្រាប់ប្រទេសកម្ពុជា *

១. គណៈកម្មាធិការបានពិចារណាទៅលើរបាយការណ៍តាមកាលកំណត់លើកទី៦ របស់ប្រទេសកម្ពុជា (CEDAW/C/KHM/6) នៅក្នុងកិច្ចប្រជុំលើកទី១៧៣០ និង១៧៣១ (សូមមើល CEDAW/C/SR.1730 និង CEDAW/C/SR.1731) ដែលបានរៀបចំឡើងនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩។ បញ្ជីសំណួរ និងបញ្ជីបញ្ហារបស់គណៈកម្មាធិការមាននៅក្នុង CEDAW/C/KHM/Q/6 ហើយការឆ្លើយតបរបស់ប្រទេសកម្ពុជា មាននៅក្នុង CEDAW/C/KHM/Q/6/Add.1. ។

## ក. សេចក្ដីផ្ដើម

២. គណៈកម្មាធិការ សូមកោតសរសើរចំពោះរដ្ឋភាគីសម្រាប់ការដាក់របាយការណ៍តាមកាលកំណត់លើកទីប្រាំមួយ។ គណៈកម្មាធិការ ក៏សូមកោតសរសើរចំពោះការដាក់របាយការណ៍តាមដានរបស់រដ្ឋភាគី ទៅលើសេចក្ដីសង្កេតសន្និដ្ឋានលើកមុនរបស់គណៈកម្មាធិការ (CEDAW/C/KHM/CO/4-5/Add.1) និងការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅលើបញ្ជីបញ្ហានិងសំណួរ លើរបាយការណ៍តាមកាលកំណត់លើកទីប្រាំមួយ ក៏ដូចជាការធ្វើបទបង្ហាញផ្ទាល់មាត់ដោយគណៈប្រតិភូ និងការបញ្ជាក់បន្ថែមអោយកាន់តែច្បាស់ ដែលបានផ្ដល់តាមរយៈការឆ្លើយតបទៅនឹងសំណួរនានា ដែលបានលើកឡើងផ្ទាល់ដោយគណៈកម្មាធិការ ក្នុងអំឡុងពេលនៃកិច្ចសន្ទនា។

៣. គណៈកម្មាធិការ សូមកោតសរសើររដ្ឋភាគី ចំពោះគណៈប្រតិភូជាន់ខ្ពស់នៃរដ្ឋភាគីដែលដឹកនាំដោយ លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។ គណៈប្រតិភូ ក៏មានការចូលរួមពីតំណាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅក្រុងហ្សឺណែវ។

* Adopted by the Committee at its seventy-fourth session (21 October-8 November 2019).

19-19547 (E) 211119

## ខ. និដ្ឋភាពវិជ្ជមាន

៤. គណៈកម្មាធិការ សូមស្វាគមន៍ការវិវត្តរីកចម្រើនដែលសម្រេចបាន ចាប់តាំងពីការពិចារណាទៅលើរបាយការណ៍តាមកាលកំណត់លើកមុនរបស់រដ្ឋភាគីក្នុងឆ្នាំ២០១៣ (CEDAW/C/KHM/CO/4-5) ក្នុងការអនុវត្តកំណែទម្រង់ច្បាប់ ជាពិសេសចំពោះការអនុម័ត៖

(ក) ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដែលកំណត់អំពីលក្ខខណ្ឌតម្រូវ និងនីតិវិធីសម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ស្ត្រីនិងបុរស ដែលស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលកំពុងធ្វើការនៅក្នុងឧស្សាហកម្មកាត់ដេរ ដែលភាគច្រើនបំផុតជាស្ត្រី កាលពី ខែកក្កដា ឆ្នាំ២០១៨

(ខ) ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលមានគោលបំណងរៀបចំបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនទំនើបមួយ ផ្តោតទៅលើវិធានការបង្វែរកុមារចេញពីនីតិវិធីតុលាការ តាមរយៈការបង្កើតមណ្ឌលស្តារនីតិសម្បទា កាលពីខែមិថុនា ឆ្នាំ២០១៦

(គ) ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមានគោលបំណងក្នុងការធានាឯករាជ្យភាពប្រព័ន្ធតុលាការ កាលពីខែមិថុនា ឆ្នាំ២០១៤

(ឃ) ច្បាប់ស្តីពីការគ្រប់គ្រងអាស៊ីតខ្លាំង ក្នុងខែធ្នូ ឆ្នាំ២០១១ ដែលក្នុងនោះមានចែងអំពីលក្ខខណ្ឌ តម្រូវឲ្យមន្ទីរពេទ្យសាធារណៈផ្តល់ការថែទាំវេជ្ជសាស្ត្រ ដោយមិនបង់កម្រៃដល់ជនរងគ្រោះដោយសារការជះទឹកអាស៊ីដ ដែលភាគច្រើនជាស្ត្រី ព្រមទាំងការអនុម័តអនុក្រឹត្យលេខ៤៨ ស្តីពីបែបបទ និងលក្ខខណ្ឌនៃការគ្រប់គ្រងអាស៊ីដខ្លាំងក្នុងខែមករា ឆ្នាំ២០១៣ ដែលចែងអំពីការបង្កើនការកាត់ទោសទៅលើជនល្មើស និងបញ្ចូលបទប្បញ្ញត្តិ ដើម្បីដាក់កំហិតទៅលើការលក់និងការចែកចាយអាស៊ីតដែលមានគ្រោះថ្នាក់។

៥. គណៈកម្មាធិការ សូមស្វាគមន៍កិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ដើម្បីការកែលម្អក្របខណ្ឌស្ថាប័ន និងគោលនយោបាយឲ្យកាន់តែប្រសើរ ក្នុងគោលបំណងពន្លឿនការលុបបំបាត់ការរើសអើងទៅលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រ ដូចជា ការអនុម័តឯកសារដូចខាងក្រោម៖

(ក) ផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ ដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ២០១៤-២០១៨ (“នារីរតនៈ”)

(ខ) ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ (“NAPVAW II”) និង ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ (“NAPVAW III”)

(គ) យុទ្ធសាស្ត្រជាតិស្ដីពីសុខភាពផ្លូវភេទ និងបន្តពូជ ២០១៧-២០២០ ដែលមានគោលបំណងធានាថា មានសេវាសុខភាពផ្លូវភេទ និងបន្តពូជដ៏ទូលំទូលាយមួយ អាចរកបាននៅគ្រប់កន្លែងផ្ដល់សេវាទាំងអស់

(ឃ) ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលមានគោលបំណងកសាងប្រព័ន្ធគាំពារសង្គម ប្រកបដោយប្រសិទ្ធផល និងមានចីរភាពខាងហិរញ្ញវត្ថុដោយរួមបញ្ចូល ទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុពីរឆ្នាំ ដែលស្ថិតនៅក្នុងស្ថានភាពក្រីក្រ

(ង) យុទ្ធសាស្ត្រចតុកោណស្ដីពីកំណើន ការងារ សមភាព និងប្រសិទ្ធភាព ដំណាក់កាលទីបី (២០១៤-២០១៨) និងដំណាក់កាលទីបួន (២០១៩-២០២៣) ដែលទទួលស្គាល់ពីសារៈសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី សម្រាប់ការអភិវឌ្ឍជាតិ។

## គ. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

៦. គណៈកម្មាធិការ សូមស្វាគមន៍ការគាំទ្រអន្តរជាតិសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសូមអំពាវនាវឲ្យសម្រេចបានសមភាពយេនឌ័រ (ក្នុងច្បាប់) និងក្នុងការអនុវត្ត (ពិតប្រាកដ) ស្របតាមបទប្បញ្ញត្តិនានាក្នុងអនុសញ្ញានេះពេញដំណើរការនៃការអនុវត្តរបៀបវារៈឆ្នាំ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គណៈកម្មាធិការ សូមរំលឹកឡើងវិញ អំពីសារៈសំខាន់នៃគោលដៅទី៥ និងអំពីការបញ្ជ្រាបគោលការណ៍សមភាព និងការមិនរើសអើងនូវគ្រប់គោលដៅទាំង១៧។ គណៈកម្មាធិការ សូមជំរុញឲ្យរដ្ឋភាគីទទួលស្គាល់ ស្ត្រីជាកម្លាំងជំរុញដល់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់រដ្ឋភាគី និងអនុម័តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនានា ដើម្បីឲ្យបានសម្រេចគោលដៅទាំងនោះ។

## ឃ. រដ្ឋសភា

៧. គណៈកម្មាធិការ សង្កត់ធ្ងន់ទៅលើតួនាទីដ៏សំខាន់នៃអំណាចនីតិប្បញ្ញត្តិ ក្នុងការធានាឲ្យមានការអនុវត្តពេញលេញទៅលើអនុសញ្ញានេះ (សូមមើលឧបសម្ព័ន្ធ A/65/38, part two, annex VI)។ គណៈកម្មាធិការ សូមអញ្ជើញរដ្ឋសភាកម្ពុជា ចាត់វិធានការចាំបាច់ ស្របតាមអាណត្តិរបស់ខ្លួន ទាក់ទងនឹងការអនុវត្តសេចក្ដីសង្កេតសន្និដ្ឋានទាំងនេះ ចន្លោះពីពេលបច្ចុប្បន្ន រហូតដល់ពេលដាក់ជូនរបាយការណ៍តាមកាលកំណត់លើកក្រោយ តាមអនុសញ្ញានេះ។

## ខ. វិស័យសំខាន់ដែលជាក្តីបារម្ភនិងអនុសាសន៍

### ក្របខណ្ឌច្បាប់

៨. គណៈកម្មាធិការ កត់សម្គាល់អំពីជំហរដែលរដ្ឋភាគី បានសង្កត់ធ្ងន់ថាបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ បានផ្តល់និយមន័យនិងហាមឃាត់ការរើសអើងទៅលើស្ត្រីប្រកបដោយប្រសិទ្ធភាព ស្របតាមអនុសញ្ញានេះ។ ក៏ប៉ុន្តែគណៈកម្មាធិការនៅតែមានក្តីបារម្ភ ដោយមិនទាន់មានបទប្បញ្ញត្តិណាមួយ នៅក្នុងរដ្ឋធម្មនុញ្ញ ដែលកំណត់និយមន័យនៃ ការរើសអើងទៅលើស្ត្រីដោយផ្ទាល់ និងដោយប្រយោលទេ ហើយក្រមព្រហ្មទណ្ឌ គ្រាន់តែហាមឃាត់ទម្រង់ជាក់លាក់នៃការរើសអើងដោយផ្ទាល់តែប៉ុណ្ណោះ ដូចជាការបដិសេធមិនឲ្យទទួលបានទំនិញ សេវាកម្ម ឬការងារជាដើម។ គណៈកម្មាធិការ ក៏កត់សម្គាល់ឃើញដែរថា ច្បាប់ដែលត្រូវបានធ្វើវិសោធនកម្មថ្មីៗនេះ មិនបានសំដៅដោះស្រាយវិសមភាពរវាងបុរសនិងស្ត្រី ប្រកបដោយប្រសិទ្ធភាពទេ គណៈកម្មាធិការមានការសោកស្តាយអំពីកង្វះខាតនៃការប៉ាន់ប្រមាណផលប៉ះពាល់យេនឌ័រ នៅពេលធ្វើការអនុម័តឬធ្វើវិសោធនកម្មច្បាប់។

៩. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ដល់រដ្ឋភាគី៖

(ក) ធានាថាលិខិតបទដ្ឋានគតិយុត្តិជាតិ បានដាក់បញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រី ដោយគ្របដណ្តប់ការរើសអើងដោយផ្ទាល់ និងដោយប្រយោលនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន រួមទាំងទម្រង់នៃការរើសអើងដែលមានការប្រទាក់ក្រឡាគ្នា ស្របតាមមាត្រា១ នៃអនុសញ្ញានេះ ដូចដែលរដ្ឋភាគីបានទទួលយក បន្ទាប់ពីការពិនិត្យឡើងវិញតាមកាលកំណត់ជាសាកលលើកទីបី ( A/HRC/41/17/Add.1, para.2 );

(ខ) ធ្វើការវាយតម្លៃប៉ាន់ប្រមាណផលប៉ះពាល់ យេនឌ័រជាលក្ខណៈប្រព័ន្ធ នៅពេលអនុម័តឬធ្វើវិសោធនកម្មច្បាប់នានា និងធានាថា ការធ្វើវិសោធនកម្មច្បាប់ទាំងនោះ នឹងជួយលើកកម្ពស់និងការពារសិទ្ធិស្ត្រី។

### ការទទួលបានយុត្តិធម៌ និងដំណោះស្រាយ

១០. គណៈកម្មាធិការ កត់សម្គាល់អំពីកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការកែលម្អការទទួលបានយុត្តិធម៌របស់ស្ត្រី ជាពិសេសក្នុងតំបន់ជនបទ ដោយរួមបញ្ចូលទាំង ការបង្កើនការបែងចែកថវិកាជាតិសម្រាប់ជំនួយផ្នែកច្បាប់ និងការបង្កើតក្រុមពិសេសនៃមេធាវីស្ម័គ្រចិត្ត ក្នុងការជួយជ្រោមជ្រែងដល់ស្ត្រីដែលស្ថិតនៅក្នុងស្ថានភាពក្រីក្រ ក្នុងការទទួលបានជំនួយផ្នែកច្បាប់។ ក៏ប៉ុន្តែ គណៈកម្មាធិការសូមបញ្ជាក់សារជាថ្មីម្តងទៀត អំពីក្តីបារម្ភដែលបានលើកឡើងពីមុន អំពីកង្វះសំណុំរឿងនៅតុលាការស្តីពីការរើសអើងទៅលើស្ត្រី នៅក្នុងរដ្ឋភាគី និងអំពីឧបសគ្គសំខាន់ៗនានា ចំពោះការទទួលបានយុត្តិធម៌ និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយសារការរំលោភបំពានទៅលើសិទ្ធិរបស់ពួកគេ ជាពិសេសស្ត្រីនៅជនបទ ស្ត្រីជនជាតិដើមភាគតិច ក្រុមស្ត្រី

ជនជាតិភាគតិច និងស្ត្រីពិការ។ ឧបសគ្គបែបនេះ រួមមាន៖

(ក) ការប្រមាថម៉ាក់ងាយពីសង្គម និងវប្បធម៌ ដែលរារាំងស្ត្រី និងក្មេងស្រីពីការដាក់បណ្តឹង ជាពិសេសទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ

(ខ) ការទទួលបានព័ត៌មានស្តីពីយន្តការ និងនីតិវិធីក្នុងការស្វែងរកដំណោះស្រាយសម្រាប់ការរំលោភបំពានសិទ្ធិស្ត្រីនិងកុមារី នៅមានកំណត់ ជាពិសេស ក្នុងតំបន់ជនបទ

(គ) កង្វះការយល់ជ្រួតជ្រាបអំពីយេនឌ័រ នៅក្នុងប្រព័ន្ធយុត្តិធម៌ ដោយរួមបញ្ចូលទាំងឥរិយាបទអវិជ្ជមានរបស់ចៅក្រម ព្រះរាជអាជ្ញា មន្ត្រីអនុវត្តច្បាប់ និងមេធាវី ចំពោះស្ត្រីដែលរាយការណ៍អំពីការរំលោភបំពានទៅលើសិទ្ធិរបស់ខ្លួន

(ឃ) អំពើពុករលួយ និងកង្វះឯករាជ្យភាពប្រព័ន្ធយុត្តិធម៌ ដែលនៅបន្តបង្ករជាឧបសគ្គដល់ការទទួលបានយុត្តិធម៌របស់ស្ត្រី។

១១. រំលឹកដល់អនុសាសន៍ទូទៅលេខ ៣៣ (២០១៥) ស្តីពីការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរ៖

(ក) រៀបចំបង្កើតគម្រោងជំនួយផ្នែកច្បាប់ទូលំទូលាយមួយ ដែលមានការផ្តល់មូលនិធិប្រកបដោយចីរភាព រយៈពេលវែងពីថវិកាជាតិ និងបង្កើតតុលាការឧទ្ធរណ៍ថ្នាក់តំបន់ ក្រៅពីនៅរាជធានីដើម្បីធានាការទៅកាន់ និងទទួលបាននូវការដំណើរការក្តីពីតុលាការ និងសាលាជម្រះក្តីប្រកបដោយប្រសិទ្ធភាព ចំពោះស្ត្រីទាំងអស់ ជាពិសេស ស្ត្រីនៅតាមជនបទ ស្ត្រីជនជាតិដើមភាគតិច ស្ត្រីក្នុងក្រុមជាតិពន្ធុភាគតិច និងស្ត្រីមានពិការភាព

(ខ) លុបបំបាត់វប្បធម៌ប្រមាថមាក់ងាយទៅលើស្ត្រីនិងក្មេងស្រី ដែលបានដាក់ពាក្យបណ្តឹងពីការរំលោភបំពានផ្សេងៗ ទៅលើសិទ្ធិរបស់ពួកគេ តាមរយៈការលើកកម្ពស់ការយល់ដឹងដល់សាធារណៈជនទូទៅ ស្តីពីសិទ្ធិស្ត្រី

(គ) ផ្សព្វផ្សាយព័ត៌មាន ស្តីពីយន្តការ និងនីតិវិធីក្នុងការស្វែងរកដំណោះស្រាយចំពោះការរំលោភបំពានទៅលើសិទ្ធិស្ត្រី និងក្មេងស្រី ជាពិសេសនៅតាមតំបន់ជនបទ

(ឃ) ពង្រឹងការឆ្លើយតបតម្រូវការយេនឌ័រ និងការយល់ដឹងជ្រួតជ្រាប អំពីយេនឌ័រនៃប្រព័ន្ធយុត្តិធម៌ ដោយរួមបញ្ចូលទាំង ការធ្វើឡើងតាមរយៈការបង្កើនចំនួនស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌ និងផ្តល់វគ្គកសាងសមត្ថភាពដែលមានលក្ខណៈជាប្រព័ន្ធ ទៅដល់ ចៅក្រម ព្រះរាជអាជ្ញា នគរបាល និងមន្ត្រីអនុវត្តច្បាប់ផ្សេងទៀតស្តីពីអនុសញ្ញានេះក៏ដូចជាសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការយុត្តាធិការក្រោមពិធីសារបន្ថែម ព្រមទាំងអនុសាសន៍ទូទៅរបស់អនុសញ្ញានេះ។

(ង) ចាត់វិធានការជាក់លាក់ ដើម្បីពង្រឹងឯករាជ្យភាព និងភាពមិនលម្អៀង នៃប្រព័ន្ធយុត្តិធម៌ និងធានាថា ករណីរើសអើងផ្អែកលើយេនឌ័រ និងអំពើហិង្សាលើស្ត្រី រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ត្រូវបានស៊ើបអង្កេតពេញលេញ ដោយជនល្មើសត្រូវបានកាត់ទោស និងទទួលទណ្ឌកម្ម ហើយជនរងគ្រោះទទួលបានដំណោះស្រាយគ្រប់គ្រាន់ ។

(ច) ពង្រឹងវិធានការនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយរួមបញ្ចូលទាំងតាមរយៈការអនុម័តនិងការអនុវត្តវិធានការវិន័យ ដែលមានប្រសិទ្ធភាព ដើម្បីធ្វើឲ្យមន្ត្រីរដ្ឋាភិបាលមានគណនេយ្យភាពចំពោះអំពើពុករលួយ ក្នុងគោលបំណងដើម្បីស្តារឡើងវិញ នូវទំនុកចិត្តរបស់ស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌។

១២. គណៈកម្មាធិការ កត់សម្គាល់អំពីការសម្រេចចិត្តខាងក្រោមនេះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងសំណុំរឿង ០០២/០២ ដែលបានអនុវត្តគម្រោងសំណងចំនួន ១៣ ក្នុងទូទាំងប្រទេសរបស់រដ្ឋភាគី ដែលទទួលស្គាល់ជនរងគ្រោះជាផ្លូវការ ដើម្បីបង្កើតការចងចាំជាសមូហភាព និងការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ដោយរួមទាំងជនរងគ្រោះដោយការរំលោភសេពសន្ថវៈ នៅក្នុងបរិបទនៃការរៀបអាពាហ៍-ពិពាហ៍ដោយបង្ខំ។ ក៏ប៉ុន្តែ គណៈកម្មាធិការមានការសោកស្តាយ ដែលគម្រោងទាំងនេះមិនបានទទួលស្គាល់ ឬផ្តល់នូវដំណោះស្រាយសំណង ប្រកបដោយប្រសិទ្ធភាពឲ្យបានគ្រប់គ្រាន់ ដល់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ ដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមនៅឡើយ ដោយរួមទាំងការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំ។ គណៈកម្មាធិការ ក៏នៅមានក្តីបារម្ភចំពោះការអនុវត្តមិនបានគ្រប់គ្រាន់ ទៅលើគោលការណ៍ដែលមាននៅក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ១៣២៥ (២០០០) ស្តីពី ស្ត្រី និង សន្តិភាព និងសន្តិសុខ ដោយរួមមានទាំងការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការកសាងសន្តិភាព ការទប់ស្កាត់វិវាទ និងគម្រោងដោះស្រាយវិវាទ និងការដាក់បញ្ចូលទស្សនៈយេនឌ័រ នៅក្នុងបេសកកម្មកសាងសន្តិភាព និងការរក្សាសន្តិភាព។

១៣. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគី៖

(ក) ផ្តល់សំណងប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះទាំងអស់ នៃអំពើហិង្សាផ្លូវភេទនិងអំពើហិង្សាផ្អែកលើយេនឌ័រ ក្នុងអំឡុងរបបខ្មែរក្រហម ដោយរួមបញ្ចូលទាំងអំពើហិង្សាផ្អែកលើយេនឌ័រទៅលើស្ត្រី ក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងសូមពិចារណាក្នុងការរៀបចំបង្កើតកម្មវិធីយុត្តិធម៌អន្តរកាល ដែលមិនទាក់ទងនឹងបច្ចេកទេសតុលាការ ដោយរួមមានទាំងការផ្តល់សំណងឲ្យបានគ្រប់គ្រាននិងការគាំទ្រផ្លូវចិត្ត ព្រមទាំងការគាំទ្រដទៃទៀត ដែលមានលក្ខណៈសមស្រប

(ខ) អនុម័តផែនការសកម្មភាពជាតិទូលំទូលាយមួយ សម្រាប់ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ១៣២៥ (២០០០) និងសេចក្តីសម្រេចបន្តបន្ទាប់ទៀត ស្តីពីស្ត្រី និង សន្តិភាពនិងសន្តិសុខ

(គ) ធានាថា ស្ត្រីមានការចូលរួមពាក់ព័ន្ធពេញលេញ នៅគ្រប់ដំណាក់កាលនៃការ

ផ្តួចផ្តើមកសាងសន្តិភាព ការទប់ស្កាត់ និងការដោះស្រាយវិវាទ និងការដាក់បញ្ចូលនូវទស្សនៈយេនឌ័រ នៅក្នុងបេសកកម្មកសាងសន្តិភាព និងការរក្សាសន្តិភាព ស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ១៣២៥ (២០០០) ក៏ដូចជាស្របតាមវិសាលភាពពេញលេញនៃរបៀបវារៈស្តីពី ស្ត្រី និងសន្តិភាពនិងសន្តិសុខ របស់ក្រុមប្រឹក្សាសន្តិសុខ ដូចដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចលេខ ១៨២០ (២០០៨), ១៨៨៨ (២០០៩), ១៨៨៩ (២០១០), ១៩៦០ (២០១០), ២១០៦ (២០១៣), ២១២២ (២០១៣), ២២៤២ (២០១៥), ២៤៦៧ (២០១៩), និង ២៤៩៣ (២០១៩) ព្រមទាំងអនុសាសន៍ទូទៅរបស់គណៈកម្មាធិការលេខ ៣០ (២០១៣) ស្តីពី ស្ត្រីក្នុងស្ថានភាពនៃការទប់ស្កាត់ជម្លោះ ក្នុងពេលជម្លោះ និងក្រោយជម្លោះ។

## យន្តការជាតិដើម្បីជម្រុញស្ថានភាពស្ត្រីឲ្យប្រសើរឡើង

១៤. គណៈកម្មាធិការ សូមស្វាគមន៍ ចំពោះការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីក្នុងការដឹកនាំកិច្ចប្រឹងប្រែងក្នុងរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រ នៅក្នុងរដ្ឋភាគី។ គណៈកម្មាធិការក៏កោតសរសើរដល់រដ្ឋភាគី ក្នុងការអនុម័តគោលនយោបាយនិងផែនការសកម្មភាពនានា ដើម្បីកែលម្អស្ថានភាពរបស់ស្ត្រី ដោយរួមមានទាំង ផែនការយុទ្ធសាស្ត្រជាតិដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី (“នារីរតនៈ”) លើកទីបួន និងការធ្វើផែនការថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ក៏ដូចជាការបែងចែកថវិកា៣% នៃថវិកាជាតិសរុបសម្រាប់សកម្មភាពនានា ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅគ្រប់ក្រសួង។ ប៉ុន្តែគណៈកម្មាធិការមានក្តីបារម្ភថា ៖

(ក) តួនាទីរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅមានកម្រិត ដោយសារតែកង្វះស្វ័យភាព ក្នុងការអនុវត្តអាណត្តិរបស់ខ្លួន

(ខ) ធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដែលបែងចែកសម្រាប់ការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពផ្សេងៗ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ មិនទាន់គ្រប់គ្រាន់នៅឡើយទេ

(គ) តំណាងសង្គមស៊ីវិល រួមទាំងអង្គការសិទ្ធិស្ត្រី មិនទាន់មានការចូលរួមពេញលេញនៅក្នុងដំណើរការនៃការបង្កើតគោលនយោបាយជាតិស្តីពីយេនឌ័រលើកដំបូងនៅឡើយទេ

(ឃ) ការតាមដាននិងការវាយតម្លៃ គោលនយោបាយនិងផែនការសកម្មភាព ស្តីពីសមភាពយេនឌ័រ នៅមានភាពទន់ខ្សោយ ជាពិសេសនៅកម្រិតស្រុកនិងឃុំ។

១៥. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ដល់រដ្ឋភាគី៖

(ក) ធានាថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានស្វ័យភាព សមត្ថកិច្ច ធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដែលចាំបាច់សម្រាប់បំពេញមុខងារ ជាយន្តការជាតិដើម្បីជម្រុញស្ថានភាពស្ត្រីឲ្យប្រសើរឡើង

(ខ) បែងចែកធនធាន និងមូលនិធិគ្រប់គ្រាន់ ពីថវិកាជាតិ សម្រាប់ការអនុវត្តផែនការសកម្មភាព និងគោលនយោបាយនានា សម្រាប់សមភាពយេនឌ័រ ដោយរួមទាំង ផែនការយុទ្ធសាស្ត្រជាតិដើម្បីសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ("នារីរតនៈ ទីបួន") ២០១៩ ដល់ ២០២៣)

(គ) ធានាឲ្យមានការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាព ពីតំណាងសង្គមស៊ីវិល រួមទាំងអង្គការសិទ្ធិស្ត្រី នៅក្នុងដំណើរការនៃការបង្កើតគោលនយោបាយជាតិស្តីពីយេនឌ័រលើកដំបូង

(ឃ) បង្កើតយន្តការតាមដាននិងវាយតម្លៃ ប្រកបដោយប្រសិទ្ធភាព ទៅលើផែនការសកម្មភាព យុទ្ធសាស្ត្រ និងវិធានការទាំងអស់ ដែលបានអនុម័ត ដើម្បីធ្វើឲ្យមានការរីកចម្រើនដល់សមភាពយេនឌ័រ ក៏ដូចជាសកម្មភាពនានារបស់ក្រសួងផ្សេងៗ ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងគោលបំណងវាស់វែងពីវឌ្ឍនភាព និងផលប៉ះពាល់។

## ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ

១៦. គណៈកម្មាធិការ កត់សម្គាល់អំពីព័ត៌មានដែលគណៈប្រតិភូរដ្ឋភាគីបានផ្តល់ជូនថា យោងតាមសេចក្តីសម្រេច ដែលបានអនុម័តនៅក្នុងខែកញ្ញា ឆ្នាំ២០១៩ អង្គការសង្គមស៊ីវិលនឹងដឹកនាំសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើសេចក្តីព្រាងច្បាប់ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិមួយ។ ក៏ប៉ុន្តែគណៈកម្មាធិការ សូមសម្តែងក្តីបារម្ភថា ទោះបីជាអង្គការសង្គមស៊ីវិលបានចូលរួមនៅក្នុងការធ្វើសេចក្តីព្រាងច្បាប់មួយនេះរួចរាល់ហើយក៏ដោយ ក៏មានការរាយការណ៍មកថា សំណើរបស់ពួកគេគឺមិនត្រូវបានទទួលយកទៅពិចារណាទេ ហើយថាមិនមានការវិវត្តន៍រីកចម្រើនណាមួយ ដែលបានកើតឡើង នៅក្នុងការបង្កើតនូវស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិឯករាជ្យនៅក្នុងរដ្ឋភាគីឡើយ។

១៧. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរពន្លឿនដំណើរការនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ ស្របតាមគោលការណ៍ពាក់ព័ន្ធទៅនឹងស្ថានភាព នៃស្ថាប័នថ្នាក់ជាតិសម្រាប់លើកកម្ពស់និងការពារសិទ្ធិមនុស្ស(គោលការណ៍ទីក្រុងប៉ារីស)(សេចក្តីសម្រេចមហាសន្និបាតលេខ៤៨/១៣៤, ឧបសម្ព័ន្ធ) ដូចដែលរដ្ឋភាគីបានទទួលយក បន្ទាប់ពីការពិនិត្យឡើងវិញតាមកាលកំណត់ជាសកលលើកទី៣ របស់ខ្លួន (A/HRC/41/17/Add.1, para.2) ដោយមានអាណត្តិរឹងមាំមួយសម្រាប់លើកកម្ពស់និងការពារសិទ្ធិស្ត្រី និងដើម្បីធានាថា ទស្សនៈនិងការយល់ឃើញរបស់អង្គការសង្គមស៊ីវិល ត្រូវបានយកទៅពិចារណាប្រកបដោយប្រសិទ្ធភាព នៅក្នុងដំណើរការនេះ។

## អ្នកការពារសិទ្ធិមនុស្សជាស្ត្រី អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល

១៨. គណៈកម្មាធិការ មានការបារម្ភអំពីរបាយការណ៍នៃការបៀតបៀន និងការបំភិតបំភ័យទៅលើអ្នកការពារសិទ្ធិមនុស្សជាស្ត្រី សមាជិកសហជីព សកម្មជនដីធ្លី និងបរិស្ថាន ក៏ដូចជាសមាជិកគណបក្សប្រឆាំង ដែលត្រូវបានរំលាយកាលពីខែវិច្ឆិកា ឆ្នាំ២០១៧។ គណៈកម្មាធិការមានការបារម្ភជាពិសេសថា ស្ត្រីមិនអាចរៀបចំនិងចូលរួមនៅក្នុងការដង្ហែក្បួន ក្នុងទិវានារីអន្តរជាតិ ចាប់តាំងពីឆ្នាំ២០១៥ មក និងមានការបារម្ភថា អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ត្រូវបានគេរាយការណ៍មកថា បានទទួលរងនូវការតាមឃ្លាំមើលនិងការរឹតត្បិតទៅលើសិទ្ធិរបស់ពួកគេកាន់តែខ្លាំងឡើង ពីសំណាក់អាជ្ញាធរ ដោយរួមមានទាំងការចាប់ឃុំខ្លួនតាមទំនើងចិត្ត ដោយសារតែសកម្មភាពស្របច្បាប់របស់ពួកគេ ហើយដែលការណ៍នេះបង្កើតឱ្យមាននូវបរិយាកាសមួយ ដែលពោរពេញដោយភាពភ័យខ្លាចនិងបាក់ស្បាត (ការដាក់ពិរុទ្ធខ្លួនឯង)។

១៩. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរធានាឱ្យបានពេញលេញនូវសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ថ្នាក់ដឹកនាំសហជីព សកម្មជនដីធ្លី និងបរិស្ថាន ព្រមទាំងសមាជិកគណបក្សប្រឆាំង ជាពិសេសសិទ្ធិរបស់ពួកគេ ក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងប្រមូលផ្តុំ ដោយមិនមានការបៀតបៀន ការឃ្លាំមើល ឬការរឹតត្បិតដោយមិនសមហេតុផលឡើយ។

## វិធានការពិសេសបណ្តោះអាសន្ន

២០. គណៈកម្មាធិការ កត់សម្គាល់ព័ត៌មាន ដែលផ្តល់ដោយគណៈប្រតិភូរបស់រដ្ឋភាគី ស្តីពីកិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងវិស័យផ្សេងៗគ្នា។ ក៏ប៉ុន្តែគណៈកម្មាធិការសូមកត់សម្គាល់ដោយក្តីបារម្ភអំពី៖

(ក) កង្វះព័ត៌មានដែលផ្តល់ដោយរដ្ឋភាគី អំពីការប្រើប្រាស់វិធានការពិសេសបណ្តោះអាសន្ន នៅក្នុងរបាយការណ៍តាមកាលកំណត់របស់រដ្ឋភាគី និងក្នុងអំឡុងពេលនៃសន្ទនា

(ខ) ការអនុម័តវិធានការនានា ដែលហាក់ដូចជាពង្រឹងវិសមភាពយេនឌ័រ ជាជាងការលុបបំបាត់នូវវិសមភាពយេនឌ័រ ដោយរួមទាំងការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លីភាគច្រើន បានទៅបុរស

(គ) កង្វះវិធានការពិសេសបណ្តោះអាសន្នដែលអនុម័តដោយរដ្ឋភាគីដើម្បីដោះស្រាយស្ថានភាពដែលស្ត្រីមិនបានទទួលនូវវិសមភាពពិតប្រាកដជាមួយនឹងបុរស ជាពិសេសទាក់ទងទៅនឹងភាពជាម្ចាស់កម្មសិទ្ធិនៅលើដីធ្លី និងការទទួលបានលំនៅឋានសមរម្យ ព្រមទាំងការទទួលបាននូវឱកាសសេដ្ឋកិច្ច នៅតាមតំបន់ជនបទ។

២១. រំលឹកដល់អនុសាសន៍ទូទៅលេខ ២៥ (២០០៤) ស្តីអំពីវិធានការពិសេសបណ្តោះអាសន្ន គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរអនុម័តនូវវិធានការ ពិសេសបណ្តោះអាសន្ន រួមទាំងនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ រដ្ឋបាល និងបទប្បញ្ញត្តិផ្សេងៗទៀត គោលនយោបាយនិងការអនុវត្ត ការបែងចែក និង/ឬការបែងចែកឡើងវិញទាក់ទងនឹងធនធាន ការប្រព្រឹត្តដែលមានលក្ខណៈអនុគ្រោះ ការជ្រើសរើសមន្ត្រីតាមគោលដៅ ការចូលបម្រើការងារនិងការតំឡើងតួនាទី ព្រមទាំងប្រព័ន្ធកូតា ដើម្បីពន្លឿនការសម្រេចបានសមភាពពិតប្រាកដសម្រាប់បុរសនិងស្ត្រី នៅគ្រប់វិស័យទាំងអស់ ដែលស្ត្រីមិនទាន់មានតំណាងគ្រប់គ្រាន់ ឬស្ត្រីដែលបាត់បង់ឱកាស ដូចជា ក្រុមស្ត្រីមានពិការភាព ស្ត្រីនៅក្នុងក្រុមជាតិពន្ធុភាគតិច ស្ត្រីជនជាតិដើមភាគតិច ស្ត្រីជនបទ និងស្ត្រីវ័យចំណាស់។ គណៈកម្មាធិការ សូមផ្តល់អនុសាសន៍បន្ថែមថា រដ្ឋភាគីគួរអនុម័តវិធានការពិសេសបណ្តោះអាសន្នដូចខាងក្រោម៖

(ក) បែងចែកឡើងវិញឬផ្តល់ដីធ្លី ដើម្បីឱ្យស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការកាន់កាប់ដីធ្លី

(ខ) បង្កើនសុវត្ថិភាពនៃការកាន់កាប់កម្មសិទ្ធិ សម្រាប់ស្ត្រីដែលរស់នៅតំបន់សំណង់បណ្តោះអាសន្ន និងដើម្បីធ្វើឲ្យស្ត្រីទទួលបាននូវលំនៅឋានសមរម្យ ជាពិសេសស្ត្រីជនជាតិដើមភាគតិច ស្ត្រីដែលមកពីក្រុមជាតិពន្ធុភាគតិច និងស្ត្រីជនបទ រួមទាំងតាមរយៈយន្តការនានា ដែលបង្កើតឡើងក្រោមគោលនយោបាយលំនៅឋានជាតិ

(គ) ដើម្បីបង្កើននូវឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រីនៅតំបន់ជនបទ ដោយរួមទាំងការធ្វើឡើងតាមរយៈការអនុម័តប្រព័ន្ធកូតា។

## ផ្នត់គំនិត/ទស្សនៈសន្មត ដែលរើសអើងយេនឌ័រ

២២. គណៈកម្មាធិការ កត់សម្គាល់ដោយក្តីបារម្ភអំពីការបន្តកើតឡើងមិនឈប់ឈរនៃផ្នត់គំនិតដែលមានការរើសអើងអំពីតួនាទីនិងការទទួលខុសត្រូវរបស់ស្ត្រីនិងបុរស នៅក្នុងគ្រួសារ និងនៅក្នុងសង្គម ដែលបានចាក់ឫសគល់យ៉ាងជ្រៅ នៅក្នុងវប្បធម៌ប្រទេសកម្ពុជា និងបន្តធ្វើឱ្យមានវិសមភាពយេនឌ័រនៅក្នុងសង្គម តាមរយៈការធ្វើអោយទៅជារឿងធម្មតាចំពោះការដែលបុរសមានអំណាចលើស្ត្រី ហើយអោយស្ត្រីនៅតែរក្សាភាពស្ងៀមស្ងាត់ និងស្តាប់តាមបង្គាប់។ គណៈកម្មាធិការ មានការបារម្ភថា ផ្នត់គំនិតយេនឌ័របែបនេះ ដូចដែលមានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ស្រីនិងច្បាប់ប្រុស ក្រមអនុវត្តន៍នានាតាមបែបប្រពៃណីសម្រាប់ស្ត្រីនិងបុរស ធ្វើឱ្យការប្រើអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រី ទៅជាស្របច្បាប់ និងក្លាយជាឫសគល់មួយ ដែលបណ្តាលអោយស្ត្រីបាត់បង់ឱកាសទទួលបានតួនាទីនៅក្នុងវិស័យជាច្រើន រួមទាំងទីផ្សារការងារ ជីវភាព នយោបាយ និងជីវភាព សាធារណៈ។

២៣. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថារដ្ឋភាគី៖

(ក) ដាក់ចេញនូវយុទ្ធសាស្ត្រទូលំទូលាយមួយ ជាមួយនឹងវិធានការសកម្ម និងមាន

ចីរភាព ដែលផ្តោតលើស្ត្រីនិងបុរស នៅគ្រប់កម្រិតទាំងអស់ នៃសង្គម ដើម្បីលុបបំបាត់ផ្នត់គំនិតដែលមានលក្ខណៈរើសអើង និងឥរិយាបថបែបបិតាធិបតេយ្យ ដែលទាក់ទងជាមួយនឹងតួនាទី និងទំនួលខុសត្រូវរបស់ស្ត្រីនិងបុរស នៅក្នុងគ្រួសារនិងសង្គម

(ខ) ធានាថា ការយោងទៅលើច្បាប់ស្រី ត្រូវបានលុបបំបាត់ចោលទាំងស្រុង នៅក្នុងសាលារៀនគ្រប់កម្រិតសិក្សាទាំងអស់ និងអប់រំដល់គ្រូបង្រៀនអំពីផលប៉ះពាល់អាក្រក់ ដោយសារតែផ្នត់គំនិតដែលមានលក្ខណៈរើសអើងទាំងនោះ ព្រមទាំងពីវិធីសាស្ត្រផ្សេងទៀត ដើម្បីបង្រៀនកុមារពីសមភាពយេនឌ័រ និងតួនាទីដែលមិនមានផ្នត់គំនិតអវិជ្ជមាន របស់ស្ត្រីនិងបុរស

(គ) បន្តដាក់ចេញនូវវិធានការច្នៃប្រឌិតថ្មីៗ ដោយរួមទាំងការធ្វើឡើង តាមរយៈប្រព័ន្ធផ្សព្វផ្សាយ បណ្តាញសង្គម និងសកម្មភាពនានា ដែលផ្តោតទៅលើយុវជន ដោយសហការជាមួយថ្នាក់ដឹកនាំសង្គមស៊ីវិល និងថ្នាក់ដឹកនាំសហគមន៍ ដើម្បីពង្រឹងការយល់ដឹងអំពីសមភាពយេនឌ័រ ដើម្បីលើកកម្ពស់ភាពជាបុរសបែបវិជ្ជមាន និងដើម្បីបង្កើននូវការបង្ហាញពីផ្នត់គំនិត ដែលមិនមានលក្ខណៈលំអៀង ចំពោះបុរសនិងស្ត្រី។

## អំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រី

២៤. គណៈកម្មាធិការ សូមស្វាគមន៍កិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រទៅលើស្ត្រី ដោយរួមទាំងការអនុម័តនូវ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាទៅលើស្ត្រី (២០១៤-២០១៨) គោលនយោបាយយុទ្ធសាស្ត្រ និងស្តង់ដាអប្បបរមា ព្រមទាំងគោលការណ៍ណែនាំនានា ដើម្បីដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីនិងក្មេងស្រី។ ប៉ុន្តែគណៈកម្មាធិការក៏នៅតែមានក្តីបារម្ភអំពី៖

(ក) បទដ្ឋានក្រឹត្យក្រមសង្គមដែលទទួលយកអំពីអំពើហិង្សាផ្អែកលើយេនឌ័រទៅលើស្ត្រីនិងក្មេងស្រីជាការត្រឹមត្រូវ និងបន្ទោសជនរងគ្រោះជាជាងបន្ទោសជនល្មើស ព្រមទាំងការរីករាលដាលនៃអំពើហិង្សាបែបនេះ ក្នុងអត្រាខ្ពស់ ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាការរំលោភសេពសន្ថវៈដោយរួមទាំងការរំលោភប៉ូក ដែលត្រូវបានគេយល់ថាជាមធ្យោបាយមួយ នៃការចងសម្ព័ន្ធភាពរបស់បុរស

(ខ) ការដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចែងអំពីការសម្រុះសម្រួលនិងការផ្សះផ្សាសម្រាប់ករណី “តូចតាច/ស្រាល” នៃអំពើហិង្សាផ្លូវកាយនិងផ្លូវភេទ និងករណីទាំងអស់នៃអំពើហិង្សាផ្លូវចិត្តនិងសេដ្ឋកិច្ច ព្រមទាំងការដែលការផ្សះផ្សាក្រៅផ្លូវការដោយសមាជិកសហគមន៍ ដែលមិនមានការបណ្តុះបណ្តាលជាផ្លូវការណាមួយ នៅតែជាមធ្យោបាយចម្បង ក្នុងការដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារដដែល

(គ) ការផ្តល់សេវាចំបាច់ និងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ដែលមិនទាន់មានភាពគ្រប់គ្រាន់ ជាពិសេសក្នុងតំបន់ជនបទ

២៥. រំលឹកទៅដល់អនុសាសន៍ទូទៅលេខ ៣៥ (ឆ្នាំ២០១៧) ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ ប្រឆាំងនឹងស្ត្រី ដែលជាការធ្វើបច្ចុប្បន្នភាពទៅអនុសាសន៍ទូទៅលេខ ១៩ គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរ៖

(ក) ប៉ាន់ប្រមាណជាលក្ខណៈប្រព័ន្ធទៅលើផលប៉ះពាល់នៃវិធានការនានា ដែលបានដាក់ចេញ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រីនិងក្មេងស្រី និងបន្តស្វែងរក និងដាក់ចេញនូវវិធីសាស្ត្រថ្មីៗ ដើម្បីដោះស្រាយនូវឫសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រ ប្រឆាំងស្ត្រី និងក្មេងស្រី

(ខ) ធ្វើការត្រួតពិនិត្យស៊ីជម្រៅឡើងវិញ ទៅលើច្បាប់ស្តីអំពី ការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ព្រមទាំងធ្វើវិសោធនកម្មទៅលើបញ្ញត្តិនានា ដើម្បីកំណត់និយមន័យហាមឃាត់ និងចាត់ទុកជាបទឧក្រិដ្ឋ នូវរាល់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ដើម្បីសម្រួលដល់ដំណើរការក្នុងការទទួលបានដីកាការពារ និងដើម្បីធានាថា ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ទទួលបានសំណងប្រកបដោយប្រសិទ្ធភាព និងធានាថា ជនប្រព្រឹត្តត្រូវបានផ្តន្ទាទោសចំពោះទង្វើរបស់ខ្លួន

(គ) បង្កើនលទ្ធភាពនៃការទទួលបាន ភាពងាយស្រួល និងគុណភាព នៃសេវាចាំបាច់នានា ព្រមទាំងការគាំទ្រដល់ជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដោយរួមទាំងជំនួយផ្នែកច្បាប់ សេវាថែទាំសុខភាព និងការគាំទ្រការប្រឹក្សាផ្លូវចិត្តដល់ជនរងគ្រោះ និងបន្តស្វែងរកលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលផ្តល់សេវាកម្មចេញចូលតែមួយសម្រាប់ជនរងគ្រោះ នៃអំពើហិង្សាផ្អែកលើយេនឌ័រ

(ឃ) ប្រមូលទិន្នន័យពីអំពើហិង្សាផ្អែកលើយេនឌ័រ ប្រឆាំងនឹងស្ត្រីនិងក្មេងស្រី ជាលក្ខណៈប្រព័ន្ធ ដែលមានការបែងចែកទៅតាម អាយុ ជាតិពន្ធុ ពិការភាព ទីតាំងភូមិសាស្ត្រ និងទំនាក់ទំនងរវាងជនរងគ្រោះ និងជនប្រព្រឹត្ត។

## ការជួញដូរនិងការកេងប្រវ័ញ្ចលើពេស្យាចារ

២៦. គណៈកម្មាធិការ ទទួលស្គាល់កិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការទប់ស្កាត់និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្នុងនោះរួមមាន ការអនុម័តផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងការជួញដូរ ២០១៤-២០១៨ និង ២០១៩-២០២៣ ការពង្រឹងសមត្ថភាពស្ថាប័នរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរ និងការរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី ស្តីពីការចំណាកស្រុកដើម្បីស្វែងរកការងារនិងការជួញដូរ ជាមួយប្រទេសនានា នៅក្នុងតំបន់។ ក៏ប៉ុន្តែគណៈកម្មាធិការនៅមានក្តីបារម្ភយ៉ាងខ្លាំងថា រដ្ឋភាគីនៅតែជាប្រភពគោលដៅ និងជាប្រទេសសម្រាប់ឆ្លងកាត់ សម្រាប់ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងក្មេងស្រី ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម។ គណៈកម្មាធិការមានក្តីបារម្ភជាពិសេសអំពី៖

(ក) ការវិវឌ្ឍនៅមានកម្រិត ក្នុងការដោះស្រាយឫសគល់ នៃការជួញដូរមនុស្សនៅក្នុងរដ្ឋភាគី ដោយរួមមានទាំងភាពក្រីក្រ និងកង្វះឱកាសសេដ្ឋកិច្ច ជាពិសេសនៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាល។

(ខ) កង្វះការកំណត់អត្តសញ្ញាណ និងការបញ្ជូនជនរងគ្រោះនៃអំពើជួញដូរទៅកាន់សេវាសមស្រប ប្រកបដោយប្រសិទ្ធភាព

(គ) ការប្រើប្រាស់ច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្សដោយខុសឆ្គង ចំពោះបុគ្គលណា ដែលមិនត្រូវទទួលខុសត្រូវចំពោះបទល្មើសជួញដូរ

(ឃ) កង្វះព័ត៌មានអំពីការកាត់ទោសអ្នកជួញដូរ ក៏ដូចជាមានការលើកឡើងអំពីការបិទបញ្ចប់សំណុំរឿងជួញដូរផ្លូវភេទ តាមរយៈការដោះស្រាយដោយផ្តល់សំណងជាលុយកាក់ ជំនួសឱ្យការកាត់ទោសផ្នែកព្រហ្មទណ្ឌ និងការដាក់ទណ្ឌកម្មឱ្យបានគ្រប់គ្រាន់។

២៧. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថារដ្ឋភាគី៖

(ក) ដោះស្រាយឫសគល់នៃការជួញដូរស្ត្រីនិងក្មេងស្រីតាមរយៈការលើកកម្ពស់ឱកាសបង្កើតប្រាក់ចំណូល និងការកែលម្អស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រី ជាពិសេសនៅតាមតំបន់ជនបទ

(ខ) ធានាឱ្យមានការកំណត់អត្តសញ្ញាណ ឲ្យបានឆាប់រហ័ស និងការបញ្ជូនទៅកាន់សេវាសមស្របសម្រាប់ស្ត្រីនិងក្មេងស្រី ដែលជាជនរងគ្រោះដោយសារអំពើជួញដូរ រួមទាំងការធ្វើឡើងតាមរយៈការផ្តល់នូវការបណ្តុះបណ្តាលជាប្រព័ន្ធដល់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធទាំងអស់ ស្តីពីការអនុវត្តគោលការណ៍ណែនាំអំពីការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព

(គ) ធានាឱ្យមានការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងសង្គម ដោយរួមទាំងការធ្វើឡើង តាមរយៈការផ្តល់ឱ្យពួកគេនូវការការពារប្រកបដោយប្រសិទ្ធភាព រួមមានការផ្តល់ជម្រកសុវត្ថិភាព ជំនួយ និងដំណោះស្រាយលើសំណងនៃការខូចខាតនានា ព្រមទាំងផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការគាំទ្រតាមទម្រង់ផ្សេងៗទៀត ដល់អង្គការសង្គមស៊ីវិលដែលផ្តល់ជំនួយដល់ស្ត្រី ជាជនរងគ្រោះដោយសារអំពើជួញដូរ

(ឃ) ធានាថា ស្ត្រីដែលជាជនរងគ្រោះដោយសារអំពើជួញដូរ ត្រូវបានលើកលែងពីការទទួលខុសត្រូវនានា និងត្រូវផ្តល់ឱ្យពួកគេនូវការការពារគ្រប់គ្រាន់ ដូចជាកម្មវិធីការពារសាក្សី និងផ្តល់លិខិតស្នាក់នៅបណ្តោះអាសន្ន ដោយមិនគិតអំពីសមត្ថភាពឬឆន្ទៈរបស់ពួកគេ ក្នុងការសហការជាមួយអាជ្ញាធរពាក់ព័ន្ធនឹងការកាត់ក្តីឡើយ

(ង) ធានាថា អ្នកជួញដូរ និងតួអង្គផ្សេងទៀត ដែលចូលរួមពាក់ព័ន្ធនៅក្នុងអំពើជួញដូរ ត្រូវបានកាត់ទោស និងត្រូវបានទទួលទណ្ឌកម្មគ្រប់គ្រាន់

(ច) ធានាថា វិធានការប្រយុទ្ធប្រឆាំងអំពើជួញដូរ រួមទាំងច្បាប់ស្តីពីការប្រឆាំងការជួញដូរ ត្រូវបានប្រើក្នុងគោលបំណងដើម្បីកាត់ទោសទៅលើអ្នកជួញដូរ និងផ្តល់នូវដំណោះស្រាយសំណង ប្រកបដោយប្រសិទ្ធភាពដល់ជនរងគ្រោះ ហើយធានាថា ច្បាប់ទាំងអស់នោះ មិនត្រូវបានប្រើប្រាស់ ដោយខុសគោលដៅ ទៅលើបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងទទួលខុសត្រូវលើបទល្មើសនៃការជួញដូរឡើយ។

២៨. គណៈកម្មាធិការមានក្តីបារម្ភថាស្ត្រី និងក្មេងស្រីជាច្រើនត្រូវបានកេងប្រវ័ញ្ចនៅក្នុងពេស្យាចារ នៅក្នុងរដ្ឋភាគី ហើយស្ត្រីដែលប្រកបរបរផ្លូវភេទត្រូវបានគេចាត់ទុកជា ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ សម្រាប់ទង្វើដែលធ្វើឡើងនៅទីសាធារណៈ ខណៈអ្នកដែលកេងប្រវ័ញ្ចលើស្ត្រីក្នុងអាជីវកម្មផ្លូវភេទនេះ កម្រត្រូវបានយកមកកាត់ទោសណាស់។ គណៈកម្មាធិការក៏សម្តែងនូវក្តីបារម្ភ ចំពោះកង្វះខាតវិធានការប្រកបដោយប្រសិទ្ធភាព ដែលរដ្ឋភាគីបានចាត់ឡើង ដើម្បីដោះស្រាយនូវបុព្វហេតុជាឫសគល់នៃអំពើពេស្យាចារ និងតម្រូវការនៃអាជីវកម្មផ្លូវភេទ ក៏ដូចជាក្នុងការជួយជ្រោមជ្រែងដល់ស្ត្រីនិងក្មេងស្រីដែលមានបំណងចង់ចាកចេញពីការប្រកបរបរនេះ។

២៩. គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថារដ្ឋភាគី៖

(ក) ធ្វើវិសោធនកម្មលើច្បាប់ជាតិ ដើម្បីលុបចោលនូវការចាត់ទុកស្ត្រី ដែលប្រកបរបរផ្លូវភេទជាការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ

(ខ) ស៊ើបអង្កេតនិងដាក់ទណ្ឌកម្ម ទៅលើបុគ្គលដែលកេងប្រវ័ញ្ចស្ត្រីនៅក្នុងរបរផ្លូវភេទ

(គ) ដោះស្រាយនូវបុព្វហេតុជាឫសគល់នៃអំពើពេស្យាចារ ដូចជាភាពក្រីក្រ និងវិសមភាពយេនឌ័រ នៅក្នុងរចនាសម្ព័ន្ធ ក៏ដូចជា អំពីតម្រូវការនៃអាជីវកម្មផ្លូវភេទ ព្រមទាំងដាក់ចេញនូវវិធានការគោលដៅ ដើម្បីទប់ស្កាត់ស្ត្រីនៅក្នុងស្ថានភាពងាយរងគ្រោះ ពីការកេងប្រវ័ញ្ចពេស្យាចារ ដោយរួមទាំងការផ្តល់នូវកម្មវិធីសម្រាប់ចាកចេញ និងឱកាសរកប្រាក់ចំណូលផ្សេង ពីការប្រកបរបរនេះ ដល់ស្ត្រីដែលចង់ចាកចេញពីការប្រកបរបរផ្លូវភេទ

(ឃ) ផ្តល់កម្មវិធីជំនួយ កម្មវិធីស្តារនីតិសម្បទា និងកម្មវិធីសមាហរណកម្ម សម្រាប់ស្ត្រីនិងក្មេងស្រី ដែលត្រូវបានកេងប្រវ័ញ្ចនៅក្នុងពេស្យាចារ។

## ការចូលរួមនៅក្នុងជីវិតនយោបាយនិងសាធារណៈ

៣០. គណៈកម្មាធិការ សូមស្វាគន៍ចំពោះព័ត៌មានដែលផ្តល់ដោយគណៈប្រតិភូរដ្ឋភាគី ដែលថាមានការកើនឡើងនូវ ចំនួនស្ត្រីកំពុងកាន់តំណែងជាប្រធានក្រុមប្រឹក្សាឃុំចំនួន ៨% និងអនុប្រធានក្រុមប្រឹក្សាឃុំចំនួន ១៤% ក្នុងឆ្នាំ២០១៨។ ប៉ុន្តែគណៈកម្មាធិការកត់សម្គាល់ថា អាត្រានេះ នៅមានកម្រិតទាបនៅឡើយ និងមានការសោកស្តាយដែលស្ត្រីបន្តមានតំណាងតិចតួច នៅក្នុងស្ថាប័ននិតិប្បញ្ញត្តិ តួនាទីរដ្ឋមន្ត្រី និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ក៏ដូចជាក្នុងប្រព័ន្ធយុត្តិធម៌ កងកំលាំងប៉ូលីស សេវាការបរទេស និងស្ថាប័នសិក្សាធិការ ជាពិសេសនៅកម្រិតធ្វើសេចក្តីសម្រេចចិត្ត។ គណៈកម្មាធិការ ក៏មានការសោកស្តាយ ចំពោះកង្វះខាតភាពជាតំណាងនៃស្ត្រីមកពីក្រុមពន្ធភាគតិច និងស្ត្រីជនជាតិដើមភាគតិច នៅក្នុងជីវភាពនយោបាយ និងសាធារណៈ។

៣១. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ដល់រដ្ឋភាគី៖

(ក) ដាក់ចេញនូវវិធានការនានារួមទាំង វិធានការពិសេសបណ្តោះអាសន្ន ដូចជាប្រព័ន្ធកូតា ស្របតាមមាត្រា៤ កថាខណ្ឌ១ នៃអនុសញ្ញានេះ និងអនុសាសន៍ទូទៅរបស់គណៈកម្មាធិការលេខ ២៥ (២០០៤) និងអនុសាសន៍ទូទៅលេខ ២៣ (១៩៩៧) ស្តីពីស្ត្រីក្នុងវិស័យនយោបាយ និងជីវភាពសាធារណៈ ក្នុងគោលបំណងដើម្បីពន្លឿនការចូលរួមឱ្យបានពេញលេញ និងដោយសមភាពរបស់ស្ត្រី ក្នុងវិស័យនយោបាយនិងជីវភាពសាធារណៈ ដោយរួមបញ្ចូលទាំងនៅក្នុងស្ថាប័ននិតិប្បញ្ញត្តិ តួនាទីរដ្ឋមន្ត្រី និងរដ្ឋាភិបាលមូលដ្ឋាន ក៏ដូចជា នៅក្នុងប្រព័ន្ធយុត្តិធម៌ កងកម្លាំងនគរបាល សេវាការបរទេស និងស្ថាប័នសិក្សាធិការ ជាពិសេសនៅកម្រិតធ្វើសេចក្តីសម្រេចចិត្ត

(ខ) បង្កើតបរិយាកាសអំណោយផល សម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ និងជីវភាពសាធារណៈ ជាពិសេសទាក់ទងទៅនឹងស្ត្រីនៅក្នុងក្រុមជាតិពន្ធភាគតិច ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីមានពិការភាព ដោយរួមបញ្ចូលទាំង តាមរយៈការលើកកម្ពស់ការយល់ដឹងក្នុងចំណោមថ្នាក់ដឹកនាំនយោបាយ និងសាធារណៈជនទូទៅថា ការចូលរួមរបស់ស្ត្រី ដែលមានលក្ខណៈពេញលេញ ស្មើភាព ដោយសេរី និងប្រជាធិបតេយ្យ ឈរលើគោលការណ៍ស្មើភាពគ្នាជាមួយបុរស នៅក្នុងវិស័យនយោបាយនិងជីវភាពសាធារណៈ គឺជាលក្ខខណ្ឌតម្រូវចាំបាច់ ដើម្បីឱ្យមានការអនុវត្តសិទ្ធិស្ត្រីពេញលេញ។

## សញ្ជាតិ

៣២. គណៈកម្មាធិការ សូមកត់សម្គាល់ព័ត៌មានដែលផ្តល់ដោយរដ្ឋភាគីថា កុមារដែលបានកើតពីឪពុកម្តាយជាជនបរទេស ដែលបានរស់នៅដោយស្របច្បាប់នៅក្នុងរដ្ឋភាគី មានលទ្ធភាពក្នុងការទទួលបានសំបុត្រកំណើត ដែលអាចជួយជំរុញឱ្យពួកគេទទួលបានការអប់រំ និងការថែទាំសុខភាព។ ប៉ុន្តែគណៈកម្មាធិការ នៅមានការបារម្ភចំពោះរបាយការណ៍អំពីភាពលំបាក ដែលស្ត្រីជនជាតិវៀតណាម និងខ្មែរក្រោម មានការប្រឈមក្នុងការទទួលបានសំបុត្រកំណើតសម្រាប់កូនរបស់ពួកគេ ដែលបានកើតនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាអត្តសញ្ញាណប័ណ្ណជាតិសម្រាប់ពួកគេផងដែរ ដែលកត្តានេះ បានរារាំងពួកគេ និងកូនរបស់ពួកគេ ពីការទទួលបានការអប់រំ ការងារ ការថែទាំសុខភាព និងលំនៅឋាន។ គណៈកម្មាធិការ ក៏សម្តែងនូវក្តីបារម្ភអំពី កង្វះការការពារប្រកបដោយប្រសិទ្ធភាព ក្នុងការធានាថាកុមារមានកំណើតនៅក្នុងប្រទេសកម្ពុជា ដែលអាចជាជនគ្មានរដ្ឋ អាចទទួលបានសញ្ជាតិកម្ពុជា និងទទួលបានឯកសារបញ្ជាក់ពីអត្តសញ្ញាណផ្សេងៗទៀត។

## ការអប់រំ

៣៤. គណៈកម្មាធិការ សូមកោតសសើរដល់កិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការបង្កើនការទទួលបានការអប់រំសម្រាប់ក្មេងស្រីនិងស្ត្រី ដោយរួមបញ្ចូលទាំងតាមរយៈការផ្តល់អាហារូបករណ៍ដល់ក្មេងស្រីក្នុងស្ថានភាពក្រីក្រ ការផ្តល់ទីកន្លែងស្នាក់នៅក្នុងសាលារៀននៅតាមតំបន់ជនបទ និងការបង្កើតមណ្ឌលសម្រាប់អភិវឌ្ឍន៍ ដើម្បីផ្តល់ការអប់រំក្រៅប្រព័ន្ធដល់ស្ត្រី ដែលបានបោះបង់ការសិក្សាក្នុងប្រព័ន្ធ។ គណៈកម្មាធិការ ក៏សូមស្វាគមន៍ចំពោះអាត្រាអក្ខរភាព ដែលមានការកើនឡើងក្នុងចំណោមស្ត្រីនិងក្មេងស្រី ការកើនឡើងនៃអាត្រាចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងការអប់រំបឋមសិក្សា និងការដាក់បញ្ចូលនូវការអប់រំផ្នែកផ្លូវភេទទូលំទូលាយមួយ ចូលទៅក្នុងកម្មវិធីសិក្សាជាតិសម្រាប់កុមារចាប់ពីអាយុ១០ ដល់១៨ឆ្នាំ។ ក៏ប៉ុន្តែគណៈកម្មាធិការ នៅមានការបារម្ភអំពី៖

(ក) ចំនួនសាលាមធ្យមសិក្សាមិនទាន់មានគ្រប់គ្រាន់ ជាពិសេសនៅក្នុងតំបន់ជនបទ ក៏ដូចជាឧបសគ្គដទៃទៀត ចំពោះការចុះឈ្មោះនិងការបញ្ចប់ការសិក្សារបស់ក្មេងស្រី នៅកម្រិតមធ្យមសិក្សានិងឧត្តមសិក្សា ដោយរួមមានទាំងការធ្វើចំណាកស្រុករបស់ឪពុកម្តាយ ដោយសារតែភាពក្រីក្រ ពលកម្មកុមារ ពិការភាព ការទទួលខុសត្រូវក្នុងគ្រួសារ អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះនៅវ័យក្មេង

(ខ) អាត្រាទាបនៃការចុះឈ្មោះចូលរៀនរបស់ស្ត្រីនៅក្នុងការសិក្សាកម្រិតខ្ពស់ ក៏ដូចជាការប្រមូលផ្តុំរបស់ស្ត្រីនៅក្នុងជំនាញសិក្សាមួយចំនួន ដែលភាគច្រើន តាមប្រពៃណីចាត់ទុកថាជា វិស័យសម្រាប់ស្ត្រី

(គ) ការយល់ដ្រេតជ្រាបអំពីយេនឌ័រ មិនទាន់គ្រប់គ្រាន់ នៅក្នុងការអប់រំបច្ចេកទេស ការបណ្តុះបណ្តាលជំនាញ កម្មវិធីបំណិនជីវិតនានា ដែលជាការពង្រឹងទៅដល់ផ្នត់គំនិតយេនឌ័រ ដែលមានលក្ខណៈរើសអើង និងបណ្តាលឲ្យមានភាពជាតំណាងរបស់ស្ត្រីនិងក្មេងស្រី មិនគ្រប់គ្រាន់នៅក្នុងវិស័យសិក្សា និងវិថីអាជីពការងារដែលមិនមែនជាលក្ខណៈប្រពៃណី ដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

៣៥. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគី៖

(ក) បន្តចាត់វិធានការក្នុងការបង្កើនលទ្ធភាព និងភាពងាយស្រួល ក្នុងការទទួលបាននូវសាលាមធ្យមសិក្សាដែលប្រកបដោយគុណភាព ជាពិសេសនៅក្នុងតំបន់ជនបទ និងលុបបំបាត់ឧបសគ្គជាក់លាក់ដែលក្មេងស្រីប្រឈមក្នុងការចុះឈ្មោះចូលរៀន និងក្នុងការបន្តការរៀនសូត្រក្នុងកម្រិតមធ្យមសិក្សា និងកម្រិតឧត្តមសិក្សា ដែលរួមមាន ភាពក្រីក្រ ឥរិយាបថលក្ខណៈអវិជ្ជមានរបស់ឪពុកម្តាយ និងការចង់ឲ្យកូនប្រុសទទួលបានការអប់រំជាងកូនស្រី បញ្ហាពិការភាព អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះនៅវ័យក្មេង

(ខ) លើកកម្ពស់ និងលើកទឹកចិត្តក្មេងស្រី និងស្ត្រីក្នុងការចុះឈ្មោះចូលរៀន មុខវិជ្ជាសិក្សា ដែលមិនមែនជាលក្ខណៈប្រពៃណីដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា រួមបញ្ចូលទាំងតាមរយៈកម្មវិធីតម្រង់ទិស និងប្រឹក្សាយោបល់សម្រាប់ការចាប់យកអាជីព ក្នុងការអប់រំកម្រិត មធ្យមសិក្សា និងឧត្តមសិក្សា

(គ) ធានាថា គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលទៀងទាត់ និងទូលំទូលាយ អំពីសមភាពយេនឌ័រ ដើម្បីលុបបំបាត់ភាពលំអៀងយេនឌ័រ និងផ្នត់គំនិតយេនឌ័រដែលមានលក្ខណៈ រើសអើង ជាពិសេសនៅក្នុងការអប់រំបច្ចេកទេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីបំណិនជីវិត និង លើកទឹកចិត្តឱ្យមានការបង្ហាញអំពីស្ត្រីគម្រូ ដែលបានទទួលជោគជ័យ នៅក្នុងវិថីអាជីពដែលមិនមែន លក្ខណៈប្រពៃណី។

## ការងារ

៣៦. គណៈកម្មាធិការ សូមស្វាគមន៍ចំពោះអាត្រានៃការចូលរួមខ្ពស់របស់ស្ត្រី នៅក្នុងកម្លាំងការងារ នៅក្នុងរដ្ឋភាគី។ ក៏ប៉ុន្តែគណៈកម្មាធិការនៅតែមានក្តីបារម្ភអំពី៖

(ក) ការប្រមូលផ្តុំច្រើនរបស់ស្ត្រីនៅក្នុងការងារ ដែលបានប្រាក់ឈ្នួលទាប និងមិនមាន ជំនាញ រួមទាំងនៅក្នុងវិស័យវាយនភណ្ឌ ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់និងស្បែកជើង និង វិស័យសំណង់ដែលស្ត្រីបានទទួលការងារ តាមរយៈកិច្ចសន្យាការងាររយៈពេលខ្លី ឬកិច្ចសន្យាមានថេរៈ វេលាកំណត់ ដែលធ្វើឱ្យពួកគេមានលទ្ធភាពខ្សោយនៅក្នុងការចរចារជាសមូហភាព តាមរយៈសហជីព ពាណិជ្ជកម្ម និងរារាំងពួកគេពីការទទួលបានការការពារជាមូលដ្ឋាន សម្រាប់វិស័យការងារ និងអត្ថ- ប្រយោជន៍ផ្សេងៗ ដូចជាការសម្រាកលំហែមាតុភាព និងការឈប់សម្រាកដែលមានប្រាក់ឈ្នួល

(ខ) ការប្រមូលផ្តុំច្រើនរបស់ស្ត្រីនៅក្នុងវិស័យការងារក្រៅប្រព័ន្ធ រួមមានទាំងការងារ តាមផ្ទះដែលពួកគេ ត្រូវបានបន្តផាត់ចេញពីការការពារលើសន្តិសុខការងារ និងរបបសន្តិសុខសង្គម ដូចជា ប្រាក់ឈ្នួល អប្បបរមា ការផ្តល់កម្រៃសម្រាប់ការធ្វើការបន្ថែមម៉ោង និងការសម្រាកលំហែ មាតុភាព។

(គ) ឱកាសនៅមានកម្រិតសម្រាប់ស្ត្រីក្នុងការបន្តអាជីពរបស់ខ្លួន ទៅក្នុងវិស័យការងារ ក្នុងប្រព័ន្ធ ដោយសារតែការទទួលរ៉ាប់រងដោយមិនសមមាត្រនូវបន្ទុកគ្រួសារ និងការទទួលខុសត្រូវក្នុង ការថែទាំកូនមកលើពួកគេ ។

(ឃ) មិនមានច្បាប់ទូលំទូលាយមួយ ដែលកំណត់និយមន័យ និងហាមឃាត់អំពើហិង្សា និងការបៀតបៀនឲ្យមានប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ដែលត្រូវបានគេរាយការណ៍ថា មានភាពរីករាលដាលនៅក្នុងរដ្ឋភាគី ជាពិសេសនៅក្នុងឧស្សាហកម្ម កាត់ដេរ និងក្នុងខណៈពេលធ្វើដំណើរទៅធ្វើការ និងចេញពីធ្វើការវិញ

(ង) មិនទាន់មានការធានាពេញលេញនៅឡើយ នៅក្នុងច្បាប់ជាតិ ទាក់ទងជាមួយនឹងគោលការណ៍នៃការទទួលបានប្រាក់កម្រៃស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា

(ច) ស្ថានភាពនៃស្ត្រីកម្ពុជាដែលធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស ក្នុងវិស័យការងារដែលទទួលបានប្រាក់ឈ្នួលទាប ដូចជា នៅក្នុងវិស័យផលិតកម្ម ការងារតាមផ្ទះ បដិសណ្ឋារកិច្ច និងកសិកម្ម ដែលពួកគេទទួលរងនូវការរំលោភបំពាននិងការកេងប្រវ័ញ្ច។

៣៧. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថារដ្ឋភាគី៖

(ក) ចាត់វិធានការជាក់លាក់នានា ដើម្បីធានាថា ស្ត្រីដែលធ្វើការក្រោមកិច្ចសន្យាមានថេរៈវេលាកំណត់ អាចមានលទ្ធភាពអាស្រ័យផលពីសិទ្ធិរបស់ពួកគេ ក្នុងការទទួលបានសេរីភាពសមាគម និងសេរីភាពជួបប្រជុំ រួមទាំងការចូលរួមក្នុងសហជីព ដើម្បីលើកឡើងនូវក្តីបារម្ភសមស្របតាមផ្លូវច្បាប់របស់ពួកគេ អំពីលក្ខខណ្ឌការងារ ដោយមិនមានការភ័យខ្លាចអំពីការត្រូវបានបញ្ចប់កិច្ចសន្យាការងារ ក៏ដូចជាសិទ្ធិរបស់ពួកគេ ក្នុងការទទួលបាននូវអត្ថប្រយោជន៍ការងារជាមូលដ្ឋានដូចជា ការសម្រាកលំហែរមាតុភាព និងការឈប់សម្រាកដែលមានប្រាក់ឈ្នួល ដោយរួមទាំងតាមរយៈការពង្រឹងការអនុវត្តនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលបានកំណត់រយៈពេល ២ឆ្នាំ ក្នុងការប្លុកបញ្ចូលគ្នានូវការប្រើប្រាស់កិច្ចសន្យាមានថេរៈវេលាកំណត់ និងដើម្បីដាក់កំហិតទៅលើចំនួនដងនៃកិច្ចសន្យាការងារមានថេរៈវេលាកំណត់ដែលអាចបន្តបាន មុនពេលត្រូវផ្លាស់ប្តូរទៅជាកិច្ចសន្យាដែលមានថេរៈវេលាមិនកំណត់

(ខ) ធានាថា សិទ្ធិរបស់ស្ត្រីនៅក្នុងវិស័យការងារក្រៅប្រព័ន្ធ ត្រូវបានការពារប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការធ្វើវិសោធនកម្មច្បាប់ស្តីអំពីការងារ ដើម្បីឱ្យកម្មករការងារតាមផ្ទះ ទទួលបាននូវការការពារក្នុងវិស័យការងារ ដូចគ្នានឹងកម្មករក្នុងវិស័យផ្សេងទៀតដែរ និងការអនុម័តច្បាប់ស្តីអំពីរបបសន្តិសុខសង្គម ដើម្បីឱ្យកម្មករនៅក្នុងវិស័យក្រៅប្រព័ន្ធ ទទួលបាននូវអត្ថប្រយោជន៍របបសន្តិសុខសង្គមដែរ

(គ) បង្កើតឱកាសបន្ថែមទៀតសម្រាប់ស្ត្រី ក្នុងការទទួលបានការងារក្នុងប្រព័ន្ធជាពិសេសតាមរយៈការលើកកម្ពស់ការចែករំលែក ឱ្យបានស្មើគ្នានូវការទទួលខុសត្រូវក្នុងគ្រួសារ និងនៅក្នុងផ្ទះរវាងស្ត្រីនិងបុរស និងតាមរយៈការផ្តល់នូវសម្ភារៈបរិក្ខារថែទាំកុមារគ្រប់គ្រាន់ និងផ្តល់ការឈប់សម្រាកសម្រាប់ភាពជាឪពុក

(ឃ) អនុម័តនិងអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តទូលំទូលាយ ដើម្បីទប់ស្កាត់និងឆ្លើយតបនឹងអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ ដោយរួមបញ្ចូលទាំងការបៀតបៀនផ្លូវភេទ ព្រមទាំងបង្កើតនូវយន្តការទទួលបណ្តឹងឯករាជ្យមួយ ដើម្បីធានាថា ជនរងគ្រោះអាចទទួលបាននូវដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងធានាថា ជនល្មើសត្រូវបានផ្តន្ទាទោសចំពោះទង្វើរបស់ខ្លួន

(ង) ធានាថា គោលការណ៍ទទួលបានប្រាក់ឈ្នួលស្មើគ្នា សម្រាប់ការងារដែលមានតម្លៃស្មើគ្នា ត្រូវបានចែងនៅក្នុងច្បាប់ជាតិស្របតាមអនុសញ្ញា ស្តីអំពីការទទួលបានប្រាក់កម្រៃស្មើគ្នារបស់អង្គការអន្តរជាតិខាងការងារ (ILO) ឆ្នាំ១៩៥១ (លេខ១០០)

(ច) ពង្រឹងកិច្ចប្រឹងប្រែងក្នុងការការពារសិទ្ធិរបស់ស្ត្រីកម្ពុជាដែលចំណាកស្រុកទៅក្រៅប្រទេស ដោយរួមបញ្ចូលទាំង តាមរយៈការធានាថា អនុស្សរណៈនៃការយោគយល់ទ្វេភាគីជាមួយនឹងប្រទេសទទួលកម្មករចំណាកស្រុកនោះ ផ្តល់ការការពារសិទ្ធិកម្មករចំណាកស្រុកជាស្ត្រីគ្រប់គ្រាន់

(ឆ) ផ្តល់សច្ចាប័នអនុសញ្ញាអង្គការអន្តរជាតិខាងការងារILOឆ្នាំ២០១១(លេខ១៨៩) អនុសញ្ញាស្តីអំពីអំពើហិង្សានិងការបៀតបៀនឆ្នាំ២០១៩ (លេខ១៩០) និងអនុសញ្ញាស្តីអំពីការការពារមាតុភាព ILO ឆ្នាំ២០០០ (លេខ១៨៣)។

## សុខភាព

៣៨. គណៈកម្មាធិការ សូមស្វាគមន៍កិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការកែលម្អស្ថានភាពសុខភាព និងការទទួលបានសេវាថែទាំសុខភាព ដល់ស្ត្រីនិងក្មេងស្រី ដូចមានឆ្លុះបញ្ចាំងតាមរយៈការកាត់បន្ថយអត្រាមរណៈម្ដាយនិងកុមារ និងការរីករាលដាលនៃមេរោគហ៊ីវ ក៏ដូចជាការកើនឡើងនូវការប្រើប្រាស់មធ្យោបាយ ពន្យារកំណើតក្នុងចំណោមស្ត្រីដែលបានរៀបការរួច។ ប៉ុន្តែគណៈកម្មាធិការកត់សម្គាល់ដោយក្ដីបារម្ភ៖

(ក) ការទទួលបានសេវាថែទាំ និង ព័ត៌មានពីសុខភាពផ្លូវភេទនិងបន្តពូជ នៅមានកម្រិត ដោយរួមបញ្ចូលទាំងកម្រិតនៃការទទួលបានមធ្យោបាយពន្យារកំណើតបែបទំនើប និងការរំលូតកូនដោយសុវត្ថិភាព ជាពិសេសដោយស្ត្រីនិងក្មេងស្រីដែលមិនទាន់រៀបការ ព្រមទាំងការទទួលរងនូវការស្ដីការប្រមាថមាក់ងាយពីសង្គម ទៅលើស្ត្រីនិងក្មេងស្រីដែលប្រើប្រាស់សេវាទាំងនេះ ដែលនាំឱ្យមានអត្រាខ្ពស់នៃមរណៈមាតានិងការមានផ្ទៃពោះវ័យក្មេង

(ខ) ចំនួនស្ត្រីដែលស្ថិតក្នុងវ័យបង្កកំណើត គឺមានទម្ងន់មិនគ្រប់គ្រាន់ ហើយនិងជំងឺកង្វះគ្រាប់ឈាមក្រហម ជាពិសេសនៅតំបន់ជនបទ

(គ) អត្រាខ្ពស់នៃការស្លាប់ដែលពាក់ព័ន្ធនឹងជំងឺមហារីកមាត់ស្បូន និងកង្វះព័ត៌មានដែលផ្ដល់ដោយរដ្ឋភាគី ស្ដីពីវិធានការដើម្បីទប់ស្កាត់និងដោះស្រាយបញ្ហានេះ ឱ្យមានប្រសិទ្ធភាព។

៣៩. គណៈកម្មាធិការ សូមផ្ដល់អនុសាសន៍ថា រដ្ឋភាគី៖

(ក) ធានាថា សេវាកម្មនិងព័ត៌មានអំពីការថែទាំសុខភាពផ្លូវភេទនិងបន្តពូជ ដោយរួមបញ្ចូលទាំងការប្រឹក្សាយោបល់ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ ការធ្វើតេស្តនិងព្យាបាលមេរោគហ៊ីវ និងជំងឺកាមរោគ ក៏ដូចជាការរំលូតកូនដោយសុវត្ថិភាព និងសេវាក្រោយរំលូតកូន អាចរកបាន និងងាយស្រួលក្នុងការទទួលបាន សម្រាប់ស្ត្រីនិងក្មេងស្រី ជាពិសេសក្មេងស្រីវ័យជំទង់

(ខ) ចាត់វិធានការដើម្បីលុបបំបាត់ការប្រមាថមាក់ងាយពីសង្គម ដែលកើតឡើងចំពោះក្មេងស្រីនិងស្ត្រី ជាពិសេសក្មេងស្រីនិងស្ត្រីដែលមិនទាន់រៀបការ ហើយស្វែងរកសេវារំលូតកូនប្រកបដោយសុវត្ថិភាព និងពន្យារកំណើត រួមបញ្ចូលទាំងការអនុវត្តកម្មវិធីសិក្សាអំពីផ្លូវភេទទូលំទូលាយនៅតាមសាលារៀន

(គ) បញ្ចូលតម្រូវការផ្នែកអាហាររូបត្ថម្ភរបស់ស្ត្រីនិងក្មេងស្រី នៅក្នុងយុទ្ធសាស្ត្រ និងគោលនយោបាយថ្នាក់ជាតិស្ដីពីអាហារូបត្ថម្ភ ដែលមានលក្ខណៈទូលំទូលាយ ដើម្បីធានាថា តម្រូវការជាក់លាក់របស់ពួកគេ នៅគ្រប់ដំណាក់កាលនៃជីវិត ត្រូវបានបំពេញ ជាពិសេសក្នុងចំណោមស្ត្រីវ័យបង្កកំណើត នៅតាមតំបន់ជនបទ

(ឃ) ដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់នានា ប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់និងដោះស្រាយបញ្ហាមហារីកមាត់ស្បូន ដោយរួមបញ្ចូលទាំង វិធីសាស្ត្រផ្សព្វផ្សាយព័ត៌មានស្ដីពីការផ្សាភ្ជាប់រវាងវីរុសឆ្លង HPV និងជំងឺមហារីកមាត់ស្បូន ក៏ដូចជាវិធានការទប់ស្កាត់ ដែលធានាថា ស្ត្រីនិងកុមារីអាចទទួលបាននូវការពិនិត្យរកវីរុស និងជម្ងឺជាប្រចាំ។

## ស្ត្រីជនបទ

៤០. គណៈកម្មាធិការ សូមស្វាគមន៍វិធានការដែលអនុម័តដោយរដ្ឋភាគី ក្នុងការកែលម្អស្ថានភាពស្ត្រីនៅតាមជនបទ ដោយរួមបញ្ចូលទាំងការកែលម្អការទទួលបានទឹកនិងអនាម័យ និងការអនុម័តគោលនយោបាយក្នុងការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ជាមធ្យោបាយសម្រាប់ស្ត្រីក្នុងការបង្កើតប្រាក់ចំណូល។ ក៏ប៉ុន្តែគណៈកម្មាធិការនៅមានក្តីបារម្ភ អំពីការរាយការណ៍មកថា ស្ថាប័នឥណទាននានា ខ្នាតតូចបានយកអត្រាការប្រាក់ខ្ពស់ តម្រូវឱ្យមានប័ណ្ណកម្មសិទ្ធិដីធ្លីដាក់ជាទ្រព្យបញ្ចាំ និងបានផ្តោតគោលដៅទៅលើអតិថិជនក្រីក្រ ដែលភាគច្រើនគឺជាស្ត្រី ហើយនៅក្នុងករណីដែលមានការខកខានក្នុងការសងបំណុលនោះ ដីធ្លីដែលត្រូវគេរឹបអូសនោះ ជារឿយៗមានតម្លៃច្រើនខ្ពស់ជាងបំណុលដែលពួកគេជំពាក់ ដោយមិនមានការទូទាត់ត្រលប់មកវិញនូវប្រាក់ដែលសល់ពីការសងបំណុលរួចរាល់ហើយនោះឡើយ ហើយប្រការទាំងអស់នេះបានធ្វើឱ្យស្ត្រីនៅតាមជនបទជាច្រើនស្ថិតនៅសភាពទុរគ៌តនិងគ្មានផ្ទះសំបែង

៤១. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវធានាថា ស្ត្រីនៅតំបន់ជនបទអាចទទួលបានកម្ចីនិងឥណទានហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ទាប តាមរយៈការធ្វើនិយ័តកម្មប្រកបដោយប្រសិទ្ធភាពទៅលើស្ថាប័នឥណទានខ្នាតតូច និងការបង្កើតនូវយន្តការឃ្លាំមើល ដើម្បីទប់ស្កាត់នូវការអនុវត្តការផ្តល់ប្រាក់កម្ចីដែលមានលក្ខណៈកេងប្រវ័ញ្ច។ រដ្ឋភាគីគួរដាក់ចេញនូវវិធានការនានា ដើម្បីសម្របសម្រួលបង្កើនឱកាសសម្រាប់ស្ត្រីនៅតំបន់ជនបទមិនត្រឹមតែបង្កើតនូវមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមប៉ុណ្ណោះទេ គឺថែមទាំងសហគ្រាសធុនធំផងដែរ។

## បម្រែបម្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

៤២. គណៈកម្មាធិការ សូមសម្តែងនូវក្តីបារម្ភថា ស្ត្រីជាពិសេសស្ត្រីរស់នៅតំបន់ជនបទ ត្រូវបានគេផាត់ចេញពីការចូលរួម នៅក្នុងការរៀបចំបង្កើតនិងការអនុវត្តគោលនយោបាយនិងផែនការសកម្មភាពនានាស្តីពីបម្រែបម្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ថ្វីត្បិតតែតាមការពិតពួកគេទទួលរងផលប៉ះពាល់ ដោយពុំមានសមាមាត្រពីឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយដោយសារតែស្ត្រីនៅក្នុងរដ្ឋភាគី ទំនងជាពឹងផ្អែកលើវិស័យកសិកម្មច្រើនជាងបុរស។

៤៣. រំលឹកទៅដល់អនុសាសន៍ទូទៅរបស់គណៈកម្មាធិការលេខ៣៧ (២០១៨) ស្តីពីវិសាលភាពទាក់ទងនឹងយេនឌ័រ ចំពោះការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ នៅក្នុងបរិបទបម្រែបម្រួលអាកាសធាតុ គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ដល់រដ្ឋភាគី ដូចជា៖

(ក) ធានាឱ្យមានការចូលរួមរបស់ស្ត្រីប្រកបដោយប្រសិទ្ធិភាពមិនត្រឹមតែចូលរួមជាអ្នកដែលរងផលប៉ះពាល់ពីឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយប៉ុណ្ណោះទេ គឺចូលរួមជាភ្នាក់ងារនៃការផ្លាស់ប្តូរ នៅក្នុងការបង្កើតនិងអនុវត្តគោលនយោបាយនិងផែនការសកម្មភាព ស្តីពីបម្រែបម្រួលអាកាសធាតុ ការឆ្លើយតបនឹងគ្រោះមហន្តរាយ និងការកាត់បន្ថយហានិភ័យ

(ខ) ធានាថា គោលនយោបាយនិងផែនការស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្ត-រាយនិងបម្រែបម្រួលអាកាសធាតុ បានដាក់បញ្ចូលយ៉ាងច្បាស់អំពីទស្សនៈយេនឌ័រ និងពិចារណាអំពីតម្រូវការជាក់លាក់របស់ស្ត្រី ជាពិសេសស្ត្រីនៅតំបន់ជនបទ។

## ស្ត្រីជាប់ឃុំឃាំង

៤៤. គណៈកម្មាធិការ សូមស្វាគមន៍ចំពោះព័ត៌មានដែលផ្តល់ដោយរដ្ឋភាគីថា ស្ត្រីប្រើប្រាស់ថ្នាំញៀនបានទទួលការការពារជាជនរងគ្រោះ ដែលតម្រូវឱ្យមានការស្តារនីតិសម្បទា ជាជាងត្រូវបានចាត់ទុកថាជាជនល្មើស និងដែលក្រសួងយុត្តិធម៌បានចេញសារាចរមួយ ក្នុងឆ្នាំ២០១៤ ស្តីពីវិធានការជំនួសក្រៅពីការដាក់ឃុំឃាំង និងវិធានការបង្វែរ ដោយរាប់បញ្ចូលទាំងការត្រួតពិនិត្យរបស់តុលាការ ការព្យួរទោសសាកល្បង និងការងារសហគមន៍។ ក៏ប៉ុន្តែគណៈកម្មាធិការបានកត់សម្គាល់ ដោយក្តីបារម្ភអំពី៖

(ក) ការរាយការណ៍អំពីការពិចារណាមិនទាន់គ្រប់ជ្រុងជ្រោយ ដែលផ្តល់ដោយតុលាការ ចំពោះស្ថានភាពជាក់លាក់របស់ស្ត្រី នៅពេលធ្វើសេចក្តីសម្រេចអំពីការឃុំឃាំង ដែលនាំទៅដល់ការឃុំឃាំងស្ត្រីដោយមិនមានការចាំបាច់ដោយរួមបញ្ចូលទាំងស្ត្រីមានផ្ទៃពោះ និងជាម្តាយ ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងក្លាទៅលើកុមារ ដោយសារតែពួកគេត្រូវបានទុកចោល ដោយមិនមានអ្នកផ្តល់ការថែទាំចម្បង ឬត្រូវបានឃុំឃាំងជាមួយនឹងម្តាយរបស់ខ្លួននៅក្នុងស្ថានភាពមិនគ្រប់គ្រាន់

(ខ) ការរាយការណ៍ដែលថា ស្ត្រីដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានដាក់ឱ្យជាប់ជាមួយនឹងស្ត្រីដែលត្រូវបានផ្តន្ទាទោសពីបទល្មើសនានា

(គ) ការឃុំខ្លួនស្ត្រីនិងកុមារ នៅក្នុងពន្ធនាគារមានភាពចង្អៀតណែន ដែលមិនត្រឹមត្រូវតាមស្តង់ដាអន្តរជាតិ ដោយរួមទាំងការទទួលបានសេវាថែទាំសុខភាពចាំបាច់ ជាពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះ។

៤៥. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគី៖

(ក) ចាត់វិធានការជាបន្ទាន់ ដើម្បីកាត់បន្ថយចំនួនស្ត្រីជាប់ឃុំឃាំង ដោយរួមទាំងតាមរយៈការអនុវត្តសារាចរដែលចេញដោយក្រសួងយុត្តិធម៌ក្នុងឆ្នាំ២០១៤ ដើម្បីដាក់ចេញវិធានការជំនួសក្រៅពីការឃុំខ្លួន និងវិធានការបង្វែរ ដោយរួមទាំងការត្រួតពិនិត្យរបស់តុលាការ ការព្យួរទោសសាកល្បង និងការងារសេហគមន៍

(ខ) ដោះស្រាយនូវបុព្វហេតុឫសគល់នៃបទល្មើសអនីតិជន ក្នុងចំណោមស្ត្រី ដោយរួមទាំងភាពក្រីក្រ និងធានាថា ចៅក្រមពិចារណាទៅលើស្ថានភាពជាក់លាក់របស់ស្ត្រី នៅពេលធ្វើសេចក្តីសម្រេចអំពីការឃុំខ្លួន និងអំពីផលប៉ះពាល់ទៅលើកូននិងសមាជិកគ្រួសារ

(គ) កែលម្អលក្ខខណ្ឌនានា នៃមន្ទីរឃុំខ្លួនស្ត្រី ស្របតាមវិធានរបស់អង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តទៅលើអ្នកជាប់ពន្ធនាគារជាស្ត្រី និងវិធានការមិនដាក់ពន្ធនាគារសម្រាប់ជនល្មើសជាស្ត្រី (វិធានក្រុងបាងកក) និងវិធានអង្គការសហប្រជាជាតិ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធានណែលសាន់ម៉ាន់ដេឡា) ដើម្បីដោះស្រាយបញ្ហាចង្អៀតណែនណាន់ក្នុងពន្ធនាគារ និងដើម្បីធានាការផ្តល់សម្ភារៈបរិក្ខារ និងសេវាគ្រប់គ្រាន់ ជាពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលជាប់ឃុំឃាំងជាមួយនឹងកូន

## ស្ត្រីជាអ្នកពពោះជំនួស

៤៦. គណៈកម្មាធិការ កត់សម្គាល់ដោយក្តីបារម្ភថា ចាប់តាំងពីមានសេចក្តីសម្រេច ដែលអនុម័តដោយក្រសួងសុខាភិបាល ក្នុងខែតុលា ឆ្នាំ២០១៦ នៅក្នុងការដាក់ឱ្យការពពោះជំនួសគ្រប់ទម្រង់ក្លាយទៅជាបទល្មើសឧក្រិដ្ឋមក ស្ត្រីជាង ៦០នាក់ ដែលបានបំពេញតួនាទីជាអ្នកពពោះជំនួសត្រូវបានចាប់ខ្លួន ហើយទទួលរងនូវបទចោទប្រកាន់ផ្សេងៗគ្នា នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ។ គណៈកម្មាធិការ ក៏កត់សម្គាល់បន្ថែមទៀតថា ស្ត្រីមួយចំនួនក្នុងចំណោមស្ត្រីទាំងអស់ ត្រូវបានគេដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយផ្អែកទៅលើលក្ខខណ្ឌថា ពួកគេនឹងបន្តការពពោះនេះ ហើយនឹងចិញ្ចឹមកូនដែលទទួលបានពីការពពោះជំនួសនោះ ជាកូនរបស់ខ្លួនឯង រហូតដល់កូននោះ អាយុ១៨ឆ្នាំ។ គណៈកម្មាធិការ មានក្តីបារម្ភជាពិសេសថា កាតព្វកិច្ចបែបនេះ បង្កើតជាបន្ទុកផ្នែកហិរញ្ញវត្ថុ និងផ្លូវចិត្តបន្ថែមទៀត ទៅលើស្ត្រីដែលស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់ ហើយនាំឲ្យពួកគេទទួលយកនូវការពពោះជំនួសនេះ តាំងពីគ្រាដំបូងមកម្លេះ ហើយមានក្តីបារម្ភថា ពួកគេប្រឈមនឹងការរើសអើង និងប្រមាថមាក់ងាយនានា ពីសង្គម ពីក្រុមគ្រួសារ និងសហគមន៍ ដោយសារតែពួកគេបានធ្វើជាអ្នកពពោះជំនួសនេះ។

៤៧.	គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ដល់ថា រដ្ឋភាគី៖

(ក) លុបចោលសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល ដែលបានអនុម័តក្នុងខែតុលា ឆ្នាំ ២០១៦ ព្រមទាំងបញ្ចប់ការអនុវត្តការឃុំខ្លួនស្ត្រី ដែលដើរតួនាទីជាអ្នកពពោះជំនួស និងលុបចោលការអនុវត្តការដោះលែងឱ្យនៅក្រៅឃុំ ក្រោមលក្ខខណ្ឌ ដែលទាក់ទងជាមួយនឹងកាតព្វកិច្ច នៅក្នុងការបន្តការពពោះ និងត្រូវចិញ្ចឹមកូនដែលពពោះជំនួសនោះ ដោយខ្លួនឯង

(ខ) ដោះស្រាយនូវបុព្វហេតុឫសគល់នានា ដែលស្ត្រីសម្រេចចិត្តក្នុងការធ្វើជាអ្នកពពោះជំនួសនេះ ដូចជា ភាពក្រីក្រ និងតម្រូវការសងបំណុល ដោយការធានាថា ស្ត្រីដែលស្ថិតនៅស្ថានភាពក្រីក្រ អាចទទួលបានអត្ថប្រយោជន៍ផ្នែកសង្គមសេដ្ឋកិច្ច ទទួលបានប្រាក់កម្ចីដែលមានអត្រាការប្រាក់សមរម្យ និងឱកាសក្នុងការបង្កើតប្រាក់ចំណូលសមរម្យ

(គ) ធានាថា ច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនានា ស្តីពីការពពោះជំនួសនេះ ត្រូវបានពិចារណាទៅលើអតុល្យភាព នៃទំនាក់ទំនងអំណាចរវាងភាគីទាំងឡាយ ដែលមានជាប់ពាក់ព័ន្ធទៅនឹងការរៀបចំការពពោះជំនួសនេះ ជាពិសេសស្ថានភាពទន់ខ្សោយរបស់ស្ត្រីដែលធ្វើជាអ្នកពពោះជំនួសនោះ ដើម្បីទប់ស្កាត់ការដកហូតសេរីភាព និងការកេងប្រវ័ញ្ច ក៏ដូចជា ការបង្ខំ ការរើសអើង និងការប្រើប្រាស់អំពើហិង្សាទៅលើពួកគេ

(ឃ) ធានាថា សេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស មិនដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬក៏ទណ្ឌកម្មផ្នែករដ្ឋបាលណាមួយ ទៅលើស្ត្រីដែលធ្វើជាអ្នកពពោះជំនួសនោះទេ ហើយត្រូវធានាក្នុងការស្វែងរកការគាំទ្រផ្នែកបច្ចេកទេស ពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា ដើម្បីឱ្យច្បាប់នោះ អនុលោមទៅតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។

## អាពាហ៍ពិពាហ៍និងទំនាក់ទំនងគ្រួសារ

៤៨.	គណៈកម្មាធិការ សូមស្វាគមន៍ចំពោះ ការអនុម័តផែនការសកម្មភាពក្នុងការទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះវ័យជំទង់ ក្នុងខេត្តរតនៈគិរី (២០១៧-២០២១) ដែលមានគោលបំណងកាត់បន្ថយអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះរបស់យុវវ័យ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច តាមរយៈការបង្កើនការការពារនិងអន្តរាគមន៍ឆ្លើយតប។ ក៏ប៉ុន្តែ គណៈកម្មាធិការសម្តែងនូវក្តីបារម្ភថា អត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារនៅ តែមានកម្រិតខ្ពស់នៅក្នុងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ជនបទ ហើយគណៈកម្មាធិការមានការសោកស្តាយ ចំពោះកង្វះវិធានការដែលអនុម័តដោយរដ្ឋភាគីនៅខេត្តផ្សេងទៀត ក្រៅពីខេត្តរតនៈគិរី។ គណៈកម្មាធិការក៏សូមសង្កត់ធ្ងន់សារជាថ្មីម្តងទៀត អំពីក្តីបារម្ភកាលពីលើកមុនដែរថា ស្ត្រីត្រូវបានហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ឡើងវិញ នៅក្នុងរយៈពេល ១២០ថ្ងៃ ក្រោយការលែងលះ យោងតាមមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី។

៤៩. គណៈកម្មាធិការ សូមផ្ដល់អនុសាសន៍ថា រដ្ឋភាគី៖

(ក) ដាក់ចេញនូវវិធានការដែលផ្ដោតទៅលើសហគមន៍ ដែលមានអាត្រាអាពាហ៍ពិពាហ៍កុមារខ្ពស់ ដោយរួមបញ្ចូលទាំងកម្មវិធីលើកកម្ពស់ការយល់ដឹង ស្ដីពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍កុមារទៅលើសុខភាព ការអភិវឌ្ឍ និងការអប់រំរបស់ក្មេងស្រី និងពីច្បាប់ដែលកំណត់ថា ការរៀបការអាយុក្រោម ១៨ឆ្នាំ ត្រូវបានហាមឃាត់ដោយច្បាប់

(ខ) លុបចោលមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី ដែលរឹតត្បិតទាំងស្រុងទៅលើសិទ្ធិរបស់ស្ត្រីក្នុងការរៀបអាពាហ៍ពិពាហ៍ឡើងវិញ ដោយសារថាការធ្វើតេស្តរកភាពជាឪពុក អាចធ្វើឡើងតាមវិធីជំនួសផ្សេងៗទៀត និងមានលក្ខណៈមិនសូវរឹតត្បិត ដូចជាតាមរយៈការធ្វើតេស្ត ឌីអិនអេ (DNA)។

## វិសោធនកម្មមាត្រា២០ (១) នៃអនុសញ្ញា

៥០. គណៈកម្មាធិការ សូមលើកទឹកចិត្តដល់រដ្ឋភាគី ក្នុងការទទួលយកការធ្វើវិសោធនកម្មមាត្រា ២០ (១) នៃអនុសញ្ញានេះ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ស្តីពីពេលវេលាជួបប្រជុំរបស់គណៈ-កម្មាធិការ។

## សេចក្តីប្រកាសផែនការសកម្មភាពទីក្រុងប៉េកាំង

៥១. គណៈកម្មាធិការ សូមអំពាវនាវដល់រដ្ឋភាគី ក្នុងការប្រើប្រាស់សេចក្តីប្រកាសទីក្រុងប៉េកាំង និងកម្មវិធីសម្រាប់សកម្មភាព និងក្នុងការវាយតម្លៃបន្ថែមទៀត អំពីការសម្រេចបាននូវសិទ្ធិនានា ដែលមានចែងនៅក្នុងអនុសញ្ញា នៅក្នុងបរិបទនៃការពិនិត្យឡើងវិញក្រោយរយៈពេល ២៥ឆ្នាំ ទៅលើការអនុវត្តសេចក្តីប្រកាសនិងផែនការសកម្មភាពនេះ ក្នុងគោលបំណងដើម្បីសម្រេចឱ្យនូវសមភាពពិតប្រាកដរវាងស្ត្រីនិងបុរស។

## ការផ្សព្វផ្សាយ

៥២. គណៈកម្មាធិការ សំណូមពរដល់រដ្ឋភាគី ក្នុងការធានាឱ្យមានការផ្សព្វផ្សាយឱ្យបានទាន់ពេលវេលា នូវសេចក្តីសង្កេតសន្និដ្ឋានលើកនេះ ជាភាសាផ្លូវការរបស់រដ្ឋភាគី ដល់ស្ថាប័នរដ្ឋពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ (ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន) ជាពិសេសដល់រដ្ឋាភិបាល សភា និងប្រព័ន្ធយុត្តិធម៌ ដើម្បីជួយជំរុញឱ្យមានការអនុវត្តពេញលេញ។

## ការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាដទៃទៀត

៥៤. គណៈកម្មាធិការ សូមកត់សម្គាល់ថា ការគោរពអនុលោមរបស់រដ្ឋភាគី ទៅលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិចម្បងៗ ទាំង៩ នឹងជម្រុញឱ្យស្ត្រីទទួលបាន និងអាស្រ័យផលទៅលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។ ដូច្នេះហើយ គណៈកម្មាធិការ សូមលើកទឹកចិត្តដល់រដ្ឋភាគី ក្នុងការផ្តល់សច្ចាប័នអនុសញ្ញាអន្តរជាតិ ស្តីពីការការពារសិទ្ធិពលករចំណាកស្រុក និងសមាជិកក្រុមគ្រួសាររបស់ពួកគេ ដែលរដ្ឋភាគីមិនទាន់បានក្លាយទៅជារដ្ឋភាគីនៅឡើយ។

## តាមដានបន្តលើការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន

៥៥. គណៈកម្មាធិការ សំណូមពរដល់រដ្ឋភាគី ឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ២ឆ្នាំខាងមុខ អំពីវិធានការនានា ដែលបានចាត់ឡើង ដើម្បីអនុវត្តអនុសាសន៍ ដែលមានចែងក្នុងកថាខណ្ឌលេខ១៩, ២៥(ខ) និង ៤៧(ឃ) ខាងលើ។

## ការរៀបចំសម្រាប់របាយការណ៍បន្ទាប់

៥៦. គណៈកម្មាធិការ សំណូមពរឲ្យរដ្ឋភាគី ដាក់របាយការណ៍តាមការកំណត់លើកទី៧ របស់ខ្លួន ដែលនឹងត្រូវធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣។ របាយការណ៍នេះ គួរដាក់ឱ្យបានទាន់ពេលវេលា និងគ្របដណ្តប់ទៅលើរយៈពេលទាំងស្រុង ចាប់ពីពេលនេះទៅ រហូតដល់ពេលដាក់របាយការណ៍។

៥៧. គណៈកម្មាធិការ សំណូមពរឲ្យដល់រដ្ឋភាគី អនុវត្តតាមគោលការណ៍ណែនាំរួម ស្តីពីការរាយការណ៍តាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដោយរួមបញ្ចូលទាំងសេចក្តីណែនាំស្តីពីឯកសារស្នូលរួម និងឯកសារជាក់លាក់តាមសន្ធិសញ្ញា (HRI/GEN/2/Rev.6, chap. I)។

# លិខិតបទដ្ឋានគតិយុត្តិ

(កថាខណ្ឌ ០៩)

កម្ពុជាគួរតែ៖

១. ធានាថា លិខិតបទដ្ឋាន ច្បាប់ជាតិ បានដាក់បញ្ចូលនិយមន័យអំពើរើសអើងប្រឆាំងស្ត្រី ដោយគិតទាំងអំពើរើសអើងដោយផ្ទាល់ និងដោយប្រយោល ដែលកើតឡើង  តាមទីកន្លែងសាធារណៈ និងឯកជន និងរួមបញ្ចូលរាល់ទម្រង់នៃការរើសអើងអន្តរវិស័យ។

២. ធ្វើការប៉ាន់ប្រមាណលើផលប៉ះពាល់យេនឌ័រជាប្រព័ន្ធ នៅពេលអនុម័ត ឬធ្វើវិសោធនកម្មច្បាប់នានា និងធានាថា រាល់ការកែប្រែច្បាប់ទាំងនោះ បានជួយលើកកម្ពស់និងការពារសិទ្ធិស្ត្រី។

# ការទទួលបានយុត្តិធម៌

(កថាខណ្ឌ ១១)

កម្ពុជាគួរតែះ

១. បង្កើតប្រព័ន្ធគាំពារជំនួយផ្នែកច្បាប់ទូលំទូលាយ ព្រមទាំងបង្កើតសាលាឧទ្ធរណ៍ថ្នាក់តំបន់ ដើម្បីធានាថាស្ត្រីគ្រប់រូបអាចទទួលបានយុត្តិធម៌។

២. លុបបំបាត់វប្បធម៌ប្រមាថមាក់ងាយស្ត្រីដែលដាក់ពាក្យបណ្តឹងទាមទារយុត្តិធម៌ តាមរយៈការធ្វើសកម្មភាពផ្សព្វផ្សាយសាធារណៈ ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិស្ត្រី។

៣. ផ្សព្វផ្សាយព័ត៌មាននៃមធ្យោបាយនានា ដែលស្ត្រីរងគ្រោះអាចស្វែងរកដំណោះស្រាយចំពោះអំពើហិង្សាដែលរំលោភសិទ្ធិរបស់ពួកគេ ជាពិសេសនៅតំបន់ជនបទ។

៤. ពង្រឹងការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ដែលគិតគូរដល់តម្រូវការយេនឌ័រ តាមរយៈការបង្កើនចំនួនមន្ត្រីយុត្តិធម៌ជាស្ត្រី និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់។

៥. ចាត់វិធានការជាក់លាក់ដើម្បីពង្រឹងឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌ និងធានាថាអំពើហិង្សាក្នុងគ្រួសារ និងករណីរំលោភសេពសន្ថវៈត្រូវបានស៊ើបអង្កេត ជនល្មើសត្រូវបានផ្តន្ទាទោសនិងទទួលទោសទណ្ឌ ហើយជនរងគ្រោះទទួលបានដំណោះស្រាយសំណង។

៦. ពង្រឹងវិធានការលុបបំបាត់អំពើពុករលួយ ដើម្បីស្តារទំនុកចិត្តរបស់ស្ត្រី ចំពោះប្រព័ន្ធយុត្តិធម៌។

សំណោលសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# យន្តការជាតិដើម្បីជម្រុញស្ថានភាពស្ត្រីឲ្យប្រសើរឡើង
(កថាខណ្ឌ ១៥)

កម្ពុជាគួរតែ៖

១. ធានាថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានស្វ័យភាព សមត្ថកិច្ច និងធនធានគ្រប់គ្រាន់ដើម្បីអាចប្រតិបត្តិការយន្តការជាតិប្រកបដោយប្រសិទ្ធភាពធ្វើស្ថានភាពស្ត្រីបានប្រសើរឡើង។

២. បែងចែកធនធាន និងមូលនិធិគ្រប់គ្រាន់ពីកញ្ចប់ថវិកាជាតិដើម្បីអនុវត្តផែនការសកម្មភាព និងគោលនយោបាយសមភាពយេនឌ័រ។

៣. ធានាការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការនៃការបង្កើតគោលនយោបាយជាតិស្តីពី សមភាពយេនឌ័រជាលើកដំបូង។

៤. បង្កើតយន្តការវាយតម្លៃ និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ដើម្បីវាស់វែងនិងអនុវត្តសកម្មភាពដែលធ្វើឲ្យស្ថានភាពស្ត្រីបានប្រសើរឡើង។

គណៈកម្មការស៊ីដក៏បានផ្តល់អនុសាសន៍ឲ្យកម្ពុជាចាប់ផ្តើមដំណើរការនីតិវិធីដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ  ដោយផ្តល់នូវអាណត្តិច្បាស់លាស់ក្នុងការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី ដោយគិតគូរពីមតិយោបល់របស់ក្រុមសង្គមស៊ីវិលផងដែរ( កថាខណ្ឌ១៧ )។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

klahaan

# ស្ត្រីអ្នកការពារសិទ្ធិមនុស្សសង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាល

(កថាខណ្ឌ ១៩)

កម្ពុជាគួរតែធានាឲ្យបានពេញលេញនូវសិទ្ធិរបស់ស្ត្រីអ្នកការពារសិទ្ធិមនុស្ស ថ្នាក់ដឹកនាំសហជីព សកម្មជនការពារដីធ្លីនិងបរិស្ថាន និង សមាជិកគណៈបក្សប្រឆាំង ជាពិសេស សិទ្ធិនិងសេរីភាពបញ្ចេញមតិ សិទ្ធិក្នុងការជួបប្រជុំ និងបង្កើតអង្គការសមាគម ដោយគ្មានការបៀតបៀន ការឃ្លាំមើល និងស្ថិតក្រោមការរឹតត្បិតផ្សេងៗទៀត។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# វិធានការពិសេស

(កថាខណ្ឌ ២១)

កម្ពុជាគួរតែបង្កើតវិធានការពិសេស ដើម្បីពន្លឿនសមភាពពេញលេញរវាងស្ត្រីនិងបុរស នៅក្នុងគ្រប់វិស័យដែលអ្នកតំណាងរបស់ស្ត្រីនៅមានកម្រិតទាបនៅឡើយ ហើយគួរតែផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើក្រុមស្ត្រីដែលស្ថិតក្នុងស្ថានភាពមិនអំណោយផល។

វិធានការទាំងនោះ គួរដាក់បញ្ចូលៈ

១. បែងចែកនិងផ្តល់ដីធ្លីដល់ស្ត្រី ដើម្បីឲ្យស្ត្រីមានសិទ្ធិកាន់កាប់ដីធ្លី។

២. ពង្រឹងសុវត្ថិភាពនៃការកាន់កាប់របស់ស្ត្រីដែលរស់នៅលើតំបន់សំណង់បណ្តោះអាសន្ន និងធ្វើឲ្យប្រសើរឡើងនូវសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យរបស់ស្ត្រី ជាពិសេសក្រុមស្ត្រីជនជាតិភាគតិច ស្ត្រីជនជាតិដើមភាគតិច និងស្ត្រីនៅជនបទ។

៣. បង្កើនឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រីនៅជនបទ រួមបញ្ចូលទាំងការបង្កើតប្រព័ន្ធកូតាពិសេសផងដែរ។

# ទស្សនៈសន្ទតដែលរើសអើងយេនឌ័រ

(កថាខណ្ឌ ២៣)

កម្ពុជាគួរតែ៖

១. បង្កើតយុទ្ធសាស្ត្រទូលំទូលាយមួយ ដែលមានវិធានការសកម្មនិងមានចីរភាព ដោយផ្តោតលើក្រុមគោលដៅដែលជាស្ត្រីនិងបុរស នៅគ្រប់លំដាប់ថ្នាក់ក្នុងសង្គម ដើម្បីលុបបំបាត់នូវទស្សនៈសន្ទតដែលរើសអើង និងបិតាធិបតេយ្យ អំពីតួនាទីស្ត្រីនិងបុរសនៅក្នុងគ្រួសារនិងសង្គម។

២. ធានាថា រាល់ទ្រឹស្តីដែលយោងលើច្បាប់ស្ត្រីត្រូវបានលុបចោលទាំងស្រុង ពីកម្មវិធីសិក្សានៅសាលារៀន ហើយបណ្តុះបណ្តាលគ្រូបង្រៀនអំពីផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតឡើងដោយសារតែទស្សនៈសន្ទតនៅក្នុងសង្គម ព្រមទាំងផ្លាស់ប្តូរវិធីសាស្ត្រនៃការបង្រៀន ដើម្បីបញ្ជ្រាបសមភាពយេនឌ័រដល់សិស្សានុសិស្ស។

៣. បន្តបង្កើតវិធានការច្នៃប្រឌិតថ្មីៗ រួមបញ្ចូលទាំងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បណ្តាញសង្គម និងសកម្មភាពនានា ដោយផ្តោតលើយុវជន ព្រមទាំងសហការជាមួយសង្គមស៊ីវិល និងថ្នាក់ដឹកនាំសហគមន៍ ដើម្បីពង្រឹងការយល់ដឹងអំពីសមភាពយេនឌ័រ និងលុបបំបាត់ទស្សនៈសន្ទតដែលរើសអើង តាមរយៈការបង្ហាញពីសមភាពរវាងស្ត្រីនិងបុរស។



klahaan

# អំពើហិង្សាផ្អែកលើយេនឌ័រ ប្រឆាំងស្ត្រី

(កថាខណ្ឌ ២៥)

កម្ពុជាគួរតែ៖

១. វាយតម្លៃផលប៉ះពាល់នៃវិធានការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ ( GBV ) និងបន្តស្វែងរកវិធីសាស្ត្រប្រកបដោយការច្នៃប្រឌិតដើម្បីដោះស្រាយឫសគល់នៃបញ្ហា។

២. ត្រួតពិនិត្យស៊ីជម្រៅលើខ្លឹមសារនៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ( DV ) និងធ្វើវិសោធនកម្មលើមាត្រាមួយចំនួន ដើម្បីដាក់បញ្ចូលនិយមន័យ ហាមឃាត់ និងដាក់ទោសទណ្ឌលើគ្រប់ទម្រង់នៃ GBV រួមបញ្ចូលទាំង DV និងអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ សម្រួលនីតិវិធីក្នុងការស្នើសុំដីកាការពារ និងធានាថា ជនរងគ្រោះនៃ DV អាចទទួលបានដំណោះស្រាយដែលមានប្រសិទ្ធិភាព ហើយជនល្មើសត្រូវបានផ្តន្ទាទោស។

៣. បង្កើនលទ្ធភាពទទួលបាន បង្កភាពងាយស្រួល និងបង្កើនគុណភាពនៃសេវាចាំបាច់ និងផ្តល់ការគាំទ្រដល់ជនរងគ្រោះ GBV  រួមបញ្ចូល ជំនួយផ្នែកច្បាប់ សេវាថែទាំសុខភាពដែលគិតគូរដល់ជនរងគ្រោះ និងគាំទ្រការប្រឹក្សាផ្លូវចិត្តផងដែរ។

៤. ប្រមូលទិន្នន័យស្តីពី GBV ជាលក្ខណៈប្រព័ន្ធ ហើយបែងចែកទិន្នន័យទាំងនោះ ទៅតាមអាយុ ជាតិពន្ធុ ពិការភាព តំបន់ និងទំនាក់ទំនងរវាងជនរងគ្រោះនិងជនល្មើស។

# ការជួញដូរមនុស្ស (កថាខណ្ឌ ២៧)

កម្ពុជាគួរតែ៖

១. ដោះស្រាយឫសគល់នៃការជួញដូរមនុស្ស តាមរយៈការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រី ជាពិសេសស្ត្រីនៅតំបន់ជនបទ។

២. ធានាឲ្យមានការកំណត់អត្តសញ្ញាណឲ្យឆាប់រហ័ស និងការបញ្ជូនទៅកាន់សេវាសមស្របសម្រាប់ស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយសារអំពើជួញដូរ រួមទាំងតាមរយៈការផ្តល់នូវការបណ្តុះបណ្តាលជាប្រព័ន្ធដល់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធទាំងអស់ ស្តីពីការអនុវត្តគោលការណ៍ណែនាំអំពី ការកំណត់អត្តសញ្ញាណ របស់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព។

៣. ធានានូវការស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះទៅក្នុងសង្គមវិញ តាមរយៈការផ្តល់នូវការការពារប្រកបដោយប្រសិទ្ធភាព ដោយរួមបញ្ចូលទាំងការផ្តល់នូវជម្រកសុវត្ថិភាព ជំនួយ និងដំណោះស្រាយ។

៤. ធានាថា ស្ត្រីដែលជាជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានលើកលែងពីការទទួលខុសត្រូវនានា និងត្រូវផ្តល់ឲ្យពួកគេនូវការការពារគ្រប់គ្រាន់ ដូចជា កម្មវិធីការពារសាក្សី និងផ្តល់លិខិតស្នាក់នៅបណ្តោះអាសន្ន និងត្រូវផ្តល់មិនគិតអំពីសមត្ថភាព ឬឆន្ទៈរបស់ពួកគេ ក្នុងការសហការជាមួយអាជ្ញាធរពាក់ព័ន្ធនឹងការកាត់ក្តីឡើយ។

៥. ធានាថាគ្រប់ភាគីជាប់ពាក់ព័ន្ធនៅក្នុងអំពើជួញដូរមនុស្សទាំងអស់ ត្រូវបានផ្តន្ទាទោសនិងទទួលទោសទណ្ឌតាមច្បាប់។

៦. ធានាថា វិធានការដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស រួមបញ្ចូលទាំងច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស មិនត្រូវបានប្រើប្រាស់ខុសគោលដៅ ដើម្បីប្រឆាំងនឹងបុគ្គលទាំងឡាយណា ដែលមិនជាប់ពាក់ព័ន្ធនឹងករណីបទល្មើសជួញដូរមនុស្ស។

# ការកេងប្រវ័ញ្ចពេស្យាចារ

(កថាខណ្ឌ ២៨ - ២៩)

គណៈកម្មការមានក្តីបារម្ភដែលស្ត្រីនិងក្មេងស្រីជាច្រើនត្រូវបានកេងប្រវ័ញ្ចពេស្យាចារនៅកម្ពុជា ហើយស្ត្រីប្រកបរបរផ្លូវភេទត្រូវបានដាក់ទោសទណ្ឌ ដោយគ្រាន់តែធ្វើសកម្មភាពទំនាក់ទំនងឡៀវនៅតាមទីសាធារណៈ ខណៈដែលអ្នកដែលបានកេងប្រវ័ញ្ចស្ត្រីនៅក្នុងអាជីវកម្មផ្លូវភេទ មិនត្រូវបានផ្តន្ទាទោស។ ទន្ទឹមនេះ គណៈកម្មការក៏បារម្ភចំពោះស្ថានភាពកង្វះនូវវិធានការដែលមានប្រសិទ្ធិភាព ដើម្បីដោះស្រាយឫសគល់និងតម្រូវការនៃអាជីវកម្មផ្លូវភេទ ឬជួយដល់ស្ត្រីដែលប៉ុនប៉ងចាកចេញពីការប្រកបរបរផ្លូវភេទ។

កម្ពុជាគួរតែ៖

១. ធ្វើវិសោធនកម្មច្បាប់ជាតិ ដើម្បីលុបចោលនូវការចាត់ទុកស្ត្រីដែលប្រកបរបរផ្លូវភេទជាការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ

២. ស៊ើបអង្កេតនិងផ្តន្ទាទោសបុគ្គលណាដែលកេងប្រវ័ញ្ចស្ត្រីប្រកបរបរផ្លូវភេទ

៣. ដោះស្រាយឫសគល់នៃបញ្ហាពេស្យាចារ ដូចជាភាពក្រីក្រនិងវិសមភាពយេនឌ័រជាលក្ខណៈប្រព័ន្ធ ព្រមទាំងតម្រូវការនៃអាជីវកម្មផ្លូវភេទ និងបង្កើតនូវវិធានការការពារស្ត្រីពីស្ថានភាពដែលងាយរងគ្រោះពីការកេងប្រវ័ញ្ចពេស្យាចារ រួមទាំងផ្តល់កម្មវិធីនិងឱកាសនានាដល់ស្ត្រីដែលចង់ឈប់ប្រកបរបររកស៊ីផ្លូវភេទ ដើម្បីស្វែងរកប្រាក់ចំណូល។

៤. ផ្តល់ជំនួយ ស្តារនីតិសម្បទា និងកម្មវិធីសមាហរណកម្មសម្រាប់ស្ត្រីនិងក្មេងស្រីដែលត្រូវបានកេងប្រវ័ញ្ចដោយអំពើពេស្យាចារ។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# ការចូលរួមក្នុងជីវភាពនយោបាយនិងកិច្ចការសាធារណៈ

(កថាខណ្ឌ ៣១)

កម្ពុជាគួរតែ៖

១. បង្កើតវិធានការ រួមទាំងវិធានការពិសេសបណ្តោះអាសន្ន ដូចជា ការកំណត់កូតា ដើម្បីពន្លឿនសមភាព និងការចូលរួមពេញលេញរបស់ស្ត្រីក្នុងជីវភាពនយោបាយនិងកិច្ចការសាធារណៈ ជាពិសេសនៅក្នុងកម្រិតធ្វើការសម្រេចចិត្ត។

២. បង្កើតបរិយាកាសសម្រួលដល់ការចូលរួមរបស់ស្ត្រី ជាពិសេសក្រុមស្ត្រីដែលស្ថិតក្នុងស្ថានភាពមិនអំណោយផល តាមរយៈការបង្កើនការយល់ដឹងអំពីការចូលរួមដោយពេញលេញ សមភាព សេរី និងប្រជាធិបតេយ្យផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស ដើម្បីធានាការអនុវត្តសិទ្ធិស្ត្រីពេញលេញ។

# សញ្ជាតិ

(កថាខណ្ឌ ៣៣)

១. ធានានូវការទទួលបានសញ្ជាតិកម្ពុជារបស់ស្ត្រីជនភាគតិច ដែលបានបំពេញគ្រប់លក្ខខណ្ឌក្នុងការទទួលបានសញ្ជាតិ ជាពិសេសស្ត្រីដែលមានដើមកំណើតវៀតណាមនិងខ្មែរកម្ពុជាក្រោម និងធានាថាពួកគេទទួលបានការអប់រំ ការងារ សេវាថែទាំសុខភាព និងលំនៅដ្ឋាន។

២.សម្រួលនូវការទទួលបានអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងលិខិតបញ្ជាក់ពីស្ថានភាពជាស្ត្រីដែលគ្មានរដ្ឋ និងកូន។ របស់ពួកគេ ហើយត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចមិនរឹបអូសឯកសារទាំងនោះ។

៣. ផ្តល់សច្ចាប័នលើអនុសញ្ញាពាក់ព័ន្ធ ដូចជា អនុសញ្ញាស្តីពីពលរដ្ឋដែលគ្មានរដ្ឋ ឆ្នាំ១៩៥៤ និងអនុសញ្ញាស្តីពីការកាត់បន្ថយចំនួនបុគ្គលដែលគ្មានរដ្ឋ ឆ្នាំ១៩៦១។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# ការអប់រំ

(កថាខណ្ឌ ៣៥)

កម្ពុជាគួរតែ៖

១. បន្តអនុវត្តផែនការពង្រឹងគុណភាពអប់រំសិក្សាកម្រិតទុតិយភូមិ និងបង្កើនលទ្ធភាពក្នុងការទទួលបានជាពិសេសនៅតំបន់ជនបទ និងលុបបំបាត់រាល់ឧបសគ្គនានា ដែលរារាំងក្មេងស្រីមិនឲ្យចុះឈ្មោះចូលរៀននិងបន្តការសិក្សានៅកម្រិតមធ្យមសិក្សានិងទុតិយភូមិ រួមបញ្ចូលទាំងភាពក្រីក្រ ឥរិយាបថអវិជ្ជមានរបស់ឪពុកម្តាយ និងផ្នត់គំនិតដែលផ្តល់អាទិភាពខ្ពស់លើការសិក្សារបស់ក្មេងប្រុសជាងក្មេងស្រី ពិការភាព និងអាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះក្នុងវ័យក្មេង។

២. ផ្សព្វផ្សាយនិងលើកទឹកចិត្តក្មេងស្រីនិងស្ត្រីឲ្យជ្រើសរើសមុខវិជ្ជាសិក្សា ដែលទស្សនៈសង្គមសន្មតថាមិនសមស្របសម្រាប់ស្ត្រី ដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ( STEM) តាមរយៈកម្មវិធីផ្តល់ព័ត៌មាននិងការប្រឹក្សាយោបល់អំពីការជ្រើសរើសជំនាញវិជ្ជាជីវៈ និងការសិក្សានៅកម្រិតឧត្តមសិក្សា។

៣. ធានាថាគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលទៀងទាត់និងស៊ីជម្រៅអំពីសមភាពយេនឌ័រ ដើម្បីលុបបំបាត់ទស្សនៈសន្មតនៅក្នុងសង្គមដែលមានភាពរើសអើង និងលំអៀងយេនឌ័រ ជាពិសេសក្នុងកម្មវិធីសិក្សាអប់រំបច្ចេកទេស កម្មវិធីបណ្តុះបណ្តាលជំនាញ និងបំណិនជីវិត ព្រមទាំងបង្ហាញក្រុមស្ត្រីដែលជោគជ័យនៅក្នុងវិស័យការងារដែលគ្របដណ្តប់ដោយក្រុមបុរស ដើម្បីជាការលើកទឹកចិត្តនិងផ្តល់ជាគម្រូដល់ស្ត្រីវ័យក្មេង។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# ការងារ (កថាខណ្ឌ ៣៧)

កម្ពុជាគួរតែ៖

១. ធានាថាស្ត្រីដែលកំពុងបំពេញការងារក្រោមកិច្ចសន្យាការងារមានថេរៈវេលាកំណត់ ( FDCs ) អាចប្រើប្រាស់សិទ្ធិពេញលេញ ជាពិសេសសេរីភាពក្នុងការជួបប្រជុំ និងចូលរួមអង្គការ សមាគម រួមទាំងការចូលរួមជាមួយសហជីព ដោយគ្មានការភ័យខ្លាចអំពីការផ្តាច់កិច្ចសន្យាការងារ ព្រមទាំងការធានាសិទ្ធិក្នុងការទទួលបានប្រយោជន៍ផ្សេងៗ ដូចជា ការឈប់សម្រាកមាតុភាព ការឈប់សម្រាកដោយមានប្រាក់ឈ្នួល និងការអនុវត្តគោលការណ៍ដែលអនុញ្ញាតឲ្យប្រើប្រាស់ FDCs ត្រឹមរយៈពេល ២ឆ្នាំ។

២. ធានាថាសិទ្ធិរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានការពារ តាមរយៈការធ្វើវិសោធនកម្មច្បាប់ការងារ ដើម្បីផ្តល់ការការពារសិទ្ធិការងាររបស់ស្ត្រីដែលធ្វើការតាមផ្ទះ និងតាមរយៈការអនុម័តច្បាប់ស្តីពីរបបបេឡាសន្តិសុខសង្គម។

៣. បន្ថែមឱកាសសម្រាប់ស្ត្រីក្នុងការទទួលបានការតំឡើងឋានៈតួនាទីការងារ ព្រមទាំងមានការបែងចែកការទទួលខុសត្រូវស្មើគ្នារវាងបុរសនិងស្ត្រីចំពោះកិច្ចការផ្ទះ ផ្តល់មណ្ឌលទារកដ្ឋាន និងថ្ងៃឈប់សម្រាកបិតុភាពដល់បុរសជាឪពុក។

៤. អនុម័តនិងអនុវត្តលិខិតបទដ្ឋានច្បាប់ ដើម្បីការពារនិងឆ្លើយតបចំពោះអំពើហិង្សានិងការបៀតបៀននៅកន្លែងការងារ រួមបញ្ចូល អំពើបៀតបៀនផ្លូវភេទ និង បង្កើតយន្តការឯករាជ្យ ដើម្បីទទួលនិងដោះស្រាយពាក្យបណ្តឹង។

៥. ធានាថាគោលការណ៍នៃការទទួលបានប្រាក់កំរៃស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា ត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តិ។

៦. ពង្រឹងបន្ថែមចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីការពារសិទ្ធិរបស់ស្ត្រីកម្ពុជាដែលបានធ្វើចំណាកស្រុកទៅរកការងារនៅក្រៅប្រទេស។

៧. ផ្តល់សច្ចាប័នអនុសញ្ញា ILO ស្តីពីកម្មករចំណាកស្រុក ឆ្នាំ២០១១ ( លេខ ១៨៩ ) អនុសញ្ញាស្តីពីអំពើហិង្សានិងការបៀតបៀនក្នុងពិភពការងារ ( លេខខ ១៩០ ) និងអនុសញ្ញាស្តីពីកិច្ចការពារមាតុភាពឆ្នាំ២០០០ ( លេខ ១៨៣ )។

# សុខភាព

(កថាខណ្ឌ ៣៩)

កម្ពុជាគួរតែ៖

១. ធានាថាសេវាថែទាំសុខភាពផ្លូវភេទនិងបន្តពូជ និងព័ត៌មាន រួមបញ្ចូលទាំងការប្រឹក្សាយោបល់ដោយស្ម័គ្រចិត្តនិងសំងាត់ ការធ្វើតេស្តនិងព្យាបាលមេរោគហ៊ីវនិងកាមរោគ រួមទាំងសេវារំលូតកូនដោយសុវត្ថិភាពនិងការថែទាំក្រោយរំលូតកូនអាចរកបាននិងទទួលបានសម្រាប់ស្ត្រីនិងក្មេងស្រី ជាពិសេសសម្រាប់ក្មេងស្រីវ័យជំទង់។

២. ចាត់វិធានការលុបបំបាត់ការប្រមាថកេរ្តិ៍ឈ្មោះដែលកើតឡើងចំពោះក្មេងស្រីនិងស្ត្រី ជាពិសេសស្ត្រីនិងក្មេងស្រីដែលមិនបានរៀបអាពាហ៍ពិពាហ៍ ហើយស្វែងរកសេវារំលូតកូននិងពន្យារកំណើត រួមបញ្ចូលកម្មវិធីសិក្សាអប់រំទូលំទូលាយអំពីផ្លូវភេទនៅក្នុងថ្នាក់រៀន។

៣. ដាក់បញ្ចូលតម្រូវការអាហារូបត្ថម្ភរបស់ស្ត្រីនិងក្មេងស្រី នៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ ស្តីពីអាហារូបត្ថម្ភដើម្បីធានាថាតម្រូវការជាក់លាក់របស់ពួកគេ នៅគ្រប់ដំណាក់កាលនៃជីវិតត្រូវបានបំពេញ ជាពិសេសក្រុមស្ត្រីដែលស្ថិតក្នុងវ័យមានផ្ទៃពោះនៅតំបន់ជនបទ។

៤. ដាក់ចេញនូវយុទ្ធសាស្ត្រជាក់លាក់ ដើម្បីការពារនិងដោះស្រាយប្រកបដោយប្រសិទ្ធិភាព ចំពោះជំងឺមហារីកមាត់ស្បូន រួមទាំងផ្សព្វផ្សាយព័ត៌មានអំពីទំនាក់ទំនងរវាងមេរោគ HPV និងជំងឺមហារីកមាត់ស្បូន និង វិធានការការពារ ដើម្បីធានាថាស្ត្រីនិងក្មេងស្រីអាចទទួលបាននូវការពិនិត្យរកមេរោគ HPV ជាទៀងទាត់។

សំណោចសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# ស្រ្តីនៅតំបន់ជនបទ

(កថាខណ្ឌ ៤១)

១. ធានាថាស្រ្តីនៅតំបន់ជនបទអាចទទួលប្រាក់កម្ចីដែលមានការប្រាក់ទាប តាមរយៈនិយ័តកម្មប្រកបដោយប្រសិទ្ធភាពទៅលើស្ថាប័នឥណទានខ្នាតតូច និងបង្កើតយន្តការត្រួតពិនិត្យដើម្បីការពារការកេងប្រវ័ញ្ចដែលអាចកើតឡើងតាមរយៈការផ្តល់ប្រាក់កម្ចី។

២. វិធានការផ្តល់ឱកាសមិនត្រឹមតែបង្កើតនូវសហគ្រាសខ្នាត មីក្រូ តូច និងមធ្យម ប៉ុណ្ណោះទេ ថែមទាំងអាចបង្កើតសហគ្រាសខ្នាតធំផងដែរ។

# ការប្រែប្រួលអាកាសធាតុ

(កថាខណ្ឌ ៤៣)

កម្ពុជាគួរតែ៖

១. ធានាការចូលរួមពេញលេញរបស់ស្រ្តី នៅក្នុងដំណើរការនៃការបង្កើតនិងអនុវត្តគោលនយោបាយនិងផែនការសកម្មភាពនានា មិនត្រឹមតែក្នុងនាមជាអ្នកទទួលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយប៉ុណ្ណោះទេ ថែមទាំងក្នុងនាមជាភ្នាក់ងារដែលនាំឲ្យមានការផ្លាស់ប្តូរផងដែរ។

២. ធានាថាគោលនយោបាយ និងផែនការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយបានដាក់បញ្ចូលនូវតម្រូវការយេនឌ័រជាក់លាក់ និងគិតគូរដល់តម្រូវការរបស់ស្ត្រី ជាពិសេសស្ត្រីនៅតំបន់ជនបទ។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# ស្ត្រីក្នុងមន្ទីរឃុំឃាំង
(កថាខណ្ឌ ៤៥)

កម្ពុជាគួរតែ៖

១. ចាត់វិធានការបន្ទាន់ដើម្បីកាត់បន្ថយចំនួនស្ត្រីដែលស្ថិតនៅក្នុងមន្ទីរឃុំឃាំង រួមទាំងអនុវត្តសេចក្តីប្រកាសឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ដើម្បីផ្តល់ជម្រើសផ្សេងៗ ជំនួសឲ្យការឃុំខ្លួន និងវិធានការចម្រុះផ្សេងៗទៀត រួមមានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ការអនុវត្តការព្យួរទោសសាកល្បង និងការដាក់ពិន័យឲ្យធ្វើកិច្ចការសហគមន៍។

២. ដោះស្រាយឫសគល់នៃបញ្ហាបទល្មើសក្នុងចំណោមស្ត្រី ដោយគិតគូរដល់ភាពក្រីក្រ និងធានាថាចៅក្រមគិតគូរដល់ស្ថានភាពជាក់លាក់របស់ស្ត្រី ព្រមទាំងផលប៉ះពាល់នានាដែលអាចកើតឡើងដល់កូនៗ និងសមាជិកក្រុមគ្រួសារ នៅពេលធ្វើសេចក្តីសម្រេចពីការឃុំខ្លួនស្ត្រី។

៣. ធ្វើឲ្យប្រសើរឡើងនូវស្ថានភាព ទីកន្លែង និងបរិស្ថាន នៃមន្ទីរឃុំខ្លួនស្ត្រីឲ្យស្របតាម "វិធានបាងកក" និង "វិធានណែលសាន់ម៉ាន់ដឺឡា" ដោយផ្តល់សេវា និងបរិក្ខាសមស្រប ជាពិសេសសម្រាប់ស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីដែលជាប់ឃុំឃាំងជាមួយកូនៗរបស់ពួកគេ។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា

# ស្ត្រីដែលស៊ីឈ្នួលពពោះ (កថាខណ្ឌ ៤៧)

កម្ពុជាគួរតែ៖

១. បញ្ឈប់ការឃុំខ្លួនស្ត្រីដែលស៊ីឈ្នួលពពោះឲ្យគេ និងស្ត្រីរកប្រាក់ចំណូល តាមរយៈការមើលថែកុមារដែលកើតមកតាមរយៈការស៊ីឈ្នួលពពោះ។

២. ដោះស្រាយឫសគល់នៃបញ្ហាដែលនាំឲ្យមានការស៊ីឈ្នួលពពោះ ដូចជា ភាពក្រីក្រ និងការជាប់ជំពាក់បំណុល តាមរយៈការធានាថា ស្ត្រីទទួលបានផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គម ប្រាក់កម្ចីដែលមានការប្រាក់ទាប និងការងារសមរម្យ។

៣. ធានាថា ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិជាតិ ស្តីពីការស៊ីឈ្នួលពពោះ គិតគូរដល់អតុល្យភាពនៃទំនាក់ទំនងអំណាចរវាងគូភាគី ជាពិសេសស្ថានភាពទន់ខ្សោយរបស់ភាគីស្ត្រីដែលស៊ីឈ្នួលពពោះ ដើម្បីការពារការដកហូតនូវសិទ្ធិសេរីភាពនិងការកេងប្រវ័ញ្ច ព្រមទាំងការរើសអើង ការបង្ខិតបង្ខំ និងអំពើហិង្សាប្រឆាំងពួកគេ។

៤. ធានាថាសេចក្តីព្រាងច្បាប់ស្តីពីការស៊ីឈ្នួលពពោះ មិនបានកំណត់ទោសព្រហ្មទណ្ឌ និងពិន័យរដ្ឋបាលលើស្ត្រីដែលស៊ីឈ្នួលពពោះឲ្យគេ ហើយត្រូវស្វែងរកការគាំទ្របច្ចេកទេសពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីធានាថាខ្លឹមសារនៃច្បាប់នេះ ស្របតាមមាត្រដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

# ទំនាក់ទំនងអាពាហ៍ពិពាហ៍ និង គ្រួសារ (កថាខណ្ឌ ៤៩)

១. បង្កើតវិធានការដែលកំណត់គោលដៅជាក់លាក់នៅតាមសហគមន៍ ដែលមានអត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារខ្ពស់ រួមបញ្ចូលទាំងការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីការកំណត់ដោយច្បាប់ថា ការរៀបអាពាហ៍ពិពាហ៍ក្រោមអាយុ ១៨ឆ្នាំ ត្រូវបានគេហាមឃាត់ដោយច្បាប់។

២. លុបចោលមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណីដែលបានរឹតត្បិតសិទ្ធិសេរីភាពស្ត្រីក្នុងការរៀបការជាថ្មី។

សំណៅសង្ខេបនៃអនុសាសន៍របស់គណៈកម្មការ ស៊ី ដ នៃអង្គការសហប្រជាជាតិ
ក្នុងឱកាសត្រួតពិនិត្យរបាយការណ៍តាមកាលកំណត់លើកទី៦ របស់កម្ពុជា